In Acts 8, we are told how Philip baptized a certain man. *"He gave orders to stop the chariot. Then both Philip and the official went down into the water. Philip baptized him. When they came up out of the water, the Spirit of the Lord suddenly took Philip away. The official did not see him again. He went on his way full of joy."* verses 38-39. Then in Romans 6:3-4 we read Paul's words, *"All of us were baptized into Christ Jesus. Don't you know that we were baptized into his death? By being baptized, we were buried with Christ into his death. Christ has been raised from the dead by the Father's glory. And like Christ we also can live a new life."*

Paul says here in Romans 6:7, *"Those who have died have been set free from sin."* If we live for God we should not let evil things control us. We must rule them. We must cut them off with *"... the sword of the Holy Spirit. The sword is God's word."* Ephesians 6:17 (Hebrews 4:12).

Here is the battle of the Christian life. We must resist and overcome. *"The sinful nature does not want what the Spirit delights in. And the Spirit does not want what the sinful nature delights in. The two are at war with each other. That's what makes you do what you don't want to do."* Galatians 5:17. Paul goes on to say in verse 24 *"Those who belong to Christ Jesus have nailed their sinful nature to his cross. They don't want what their sinful nature loves and longs for."* Again he writes, *"So put to death anything that belongs to your earthly nature... Don't let your feelings get out of control. Remove from your life all evil longings. Stop always wanting more and more. You might as well be worshiping statues of gods."* Colossians 3:5.

Baptism is the burial of a person who is ready to die to sin, and to begin a new life in Christ. So Paul says, *"consider yourselves to be dead as far as sin is concerned. Now that you believe in Christ Jesus, consider yourselves to be alive as far as God is concerned."* Romans 6:11.

49. A New Life.

When a person is baptized they are *"born again"* John 3:3, 5, 7; (1 Peter 1:23) – not in body, but in mind. *"Like babies that were just born, you should long for the pure milk of God's word. It will help you grow up as believers."* 1 Peter 2:2.

Before baptism a person belongs to Adam's race; after baptism that person is "in Christ". Paul writes in 2 Corinthians 5:17, *"Anyone who believes in Christ*

is a new creation. The old is gone! The new has come!" The obedient believer is still mortal, but is now an heir of eternal life (Romans 8:17; Titus 1:2), adopted by God (John 1:12; Romans 8:14-19; Hebrews 2:10) and a brother or sister of the Lord Jesus Christ. They are a member of God's family.

50. Christadelphians.

This one word means *brothers of Christ* and includes people who look for the true message of the Bible, are baptised and follow the Lord Jesus Christ. It is the name that we call our Christian denomination. It is the name of Christ and the Greek word for 'brother' put together. Jesus said he is not ashamed to call them his brethren who do the will of his Father in heaven (Hebrews 2:11; Matthew 12:50).

One who follows Jesus has new hopes, new ideals, new attitudes, and a new purpose in living.

51. Seek First His Kingdom.

The central aim of this life is to *"put God's kingdom first. Do what he wants you to do. Then all of those things will also be given to you."* Matthew 6:33. Everyone should have a purpose in life. To have no aim is like drifting along in a river. Wise people will make the Kingdom of God their goal.

52. Faith Without Deeds is Useless.

God requires us to keep the Commandments of Christ and follow His son (See Exploring the Bible. Simplified version available). (James 2:20, 26)

"Love the Lord your God with all your heart and with all your soul. Love him with all your mind and with all your strength.' And here is the second one. 'Love your neighbour as you love yourself.' There is no commandment more important than these." Mark 12:30-31.

53. Love is the Fulfilment of the Law

Now, if we love the Father, we will not let the things in the world rule our hearts. James asks, *"You are not faithful to God. Don't you know that to be a friend of the world is to hate God? Anyone who chooses to be a friend of the world becomes an enemy of God."* James 4:4. (Romans 13:10).

54. Do not Love the World.

"Do not love the world or anything in it. If you love the world, love for the Father is not in you. Here is what people who belong to this world do. They try to satisfy what their sinful natures want to do. They long for what their sinful eyes look at. They brag about what they have and what they do. All of this comes from the world. It doesn't come from the Father." 1 John 2:15-17.

Everyone should think carefully about these words.

Jesus knew he was going to be killed by evil men. Even his followers ran away when he was arrested. Jesus still prayed for them. *"I do not pray that you will take them out of the world. I pray that you will keep them safe from the evil one. They do not belong to the world, just as I do not belong to it. Use the truth to make them holy. Your word is truth."* John 17:15-17.

Therefore people waiting for the coming of their King live in this world, but they do not belong to it. By teaching His words to all of the nations God will *"take out of them a people for His name"* (Acts 15:14).

55. A People for His Name.

In the same way that God called to Abraham to *"Come out!",* so He still says to everyone who wants to be His children: " '*So come out from among them and be separate,' says the Lord. 'Do not touch anything that is not pure and clean. Then I will receive you. I will be your Father. You will be my sons and daughters,' says the Lord who rules over all."* 2 Corinthians 6:17-18.

Those who have obeyed God's call to *"come out"* do not belong to *"this evil world"* (Galatians 1:4).

56. Military and Political Affairs.

God's people pray and wait for a Kingdom that will bring peace, safety and justice to the earth. Jesus Christ will be a righteous King and will destroy evil and wicked people who do not obey Him.

We are told to obey the laws of the land that we live in without disobeying the Commandments of Christ. Careful study of the Bible and prayer are needed to guide Christians when military and political decisions are made. Christadelphians believe that we should not fight in wars or vote in elections.

57. Marriage.

2 Corinthians 6:14 tells us, *"Do not be joined to unbelievers. What do right and wrong have in common? Can light and darkness be friends?"* Followers of Christ believe that marriage lasts until death or when the Lord Jesus Christ returns. Matthew 5:32 *"But here is what I tell you. Anyone who divorces his wife causes her to commit adultery. And anyone who gets married to the divorced woman commits adultery. A man may divorce his wife only if she has not been faithful to him."* Everyone who decides to get married should study God's words carefully, pray to God and talk with brothers and sisters.

To stay faithful, Christians should avoid bad habits and selfish pleasures of the world around them. Followers of Jesus are told to shine as lights, *"But God chose you to be his people. You are royal priests. You are a holy nation. You are a people who belong to God. All of this is so that you can sing his praises. He brought you out of darkness into his wonderful light."* 1 Peter 2:9. (Matthew 5:14).

58. The Memorial Meal.

On the first day of each week or as often as they meet, baptised followers of Jesus worship the Father and remember His Son in the way shown in the Bible. They eat bread (the symbol of the body) and drink poured out wine (symbol of his blood) to remember Jesus' sacrifice.

"Then Jesus took bread. He gave thanks and broke it. He handed it to them and said, 'This is my body. It is given for you. Every time you eat it, do it in memory of me.' In the same way, after the supper he took the cup. He said, 'This cup is the new covenant in my blood. It is poured out for you.'" Luke 22:19-20 (1 Corinthians 11:23-29).

By doing this, believers follow the apostles, *"On the first day of the week we met to break bread and eat together…"* Acts 20:7. Followers of Jesus *"…studied what the apostles taught. They shared life together. They broke bread and ate together. And they prayed."* Acts 2:42.

Paul encouraged believers to meet together. *"Let us not give up meeting together. Some are in the habit of doing this. Instead, let us cheer each other up with words of hope. Let us do it all the more as you see the day coming when Christ will return."* Hebrews 10:25.

59. The Building of a Character.

Christians need to behave and build a character worthy of that wonderful Kingdom which the gospel hope gives us. Jesus said, *"Suppose you start to plough and then look back. If you do, you are not fit for service in God's kingdom."* Luke 9:62. Having begun, we must never turn back.

We can learn an important lesson from the history of God's ancient people, Israel. They were called out from slavery in Egypt to go to the land of promise. God led them through the wilderness. This was their testing-time, and many thousands of them failed. When their faith was put to the test, they turned back and wanted their old life again. (Numbers 14:4) As a result, they did not reach their goal.

Paul says, *"I want to remind you about some things you already know. The Lord saved his people. He brought them out of Egypt. But later he destroyed those who did not believe."* Jude: 5 (1 Corinthians 10:1-11).

Baptism then, is the beginning of a new life. There is a proverb that says *"A journey of a thousand miles begins with a single step."* Many more steps must be taken on the journey to the Kingdom of God. In Hebrews 6:1 we read *"So let us leave the simple teachings about Christ. Let us grow up as believers."*

60. Let Us Go on to Perfection.

This is what we are called to aim at in our life following Jesus Christ. He himself is our pattern. Not only has he *"... suffered for you. He left you an example. He expects you to follow in his steps. You too were chosen to suffer."* 1 Peter 2:21, but he helps us every day to walk that path of obedience.

Paul says *"We work together with God. You are like God's field. You are like his building."* 1 Corinthians 3:9. What a partnership this is! How can it fail, unless we ourselves fail?

This great work of building a character that pleases God requires us to say no to the desires *"of your old way of life."* Ephesians 4:22-31 *"You must put away anger, rage, hate and lies. Let no dirty words come out of your mouths. Don't lie to each other. You have gotten rid of your old way of life and its habits. You have started living a new life."* Colossians 3:8-14. We also have to learn to say yes to God and learn to trust, obey and be faithful followers of His son and our future King.

Anyone who decides to follow Jesus should understand that it may bring us trials and suffering (1 John 3:2 & Philippians 3:20-21). *"God has made*

everything. He has acted in exactly the right way. He is bringing his many sons and daughters to share in his glory. To do so, he has made the One who saved them perfect because of his sufferings." Hebrews 2:10

61. Perfect Through Suffering.

The "*many sons*" cannot expect to be 'made perfect' by any other way than the way that God did with His Son. Gold is purified by fire. Gems are made beautiful by polishing. The living stones, which make up God's spiritual temple, must be shaped. (1Peter 2:5-6). Paul wrote, *"Christ Jesus himself is the most important stone in the building. The whole building is held together by him."* Ephesians 2:20-21.

"Dear friends," Peter wrote*, "don't be surprised by the painful suffering you are going through. Don't feel as if something strange were happening to you. Be joyful that you are taking part in Christ's sufferings. Then you will be filled with joy when Christ returns in glory."* 1 Peter 4:12-13. We need faith like Abraham to get us through this time of testing. We must always look to the future God has promised, and never, never give up. We are assured that *"in all things",* even those things which may seem very hard to bear, *"God works for the good of those who love him. He appointed them to be saved in keeping with his purpose."* Romans 8:28.

It is wise then, to count the cost.

62. Count the Cost.

The apostle Paul was a son of God who showed strong character to get past very difficult challenges. This is what he said after these trials: *"What we are suffering now is nothing compared with the glory that will be shown in us."* Romans 8:18. *"Our troubles are small. They last only for a short time. But they are earning for us a glory that will last forever. It is greater than all our troubles. So we don't spend all our time looking at what we can see. Instead, we look at what we can't see. What can be seen lasts only a short time. But what can't be seen will last forever."* 2 Corinthians 4:17-18 (Hebrews 11:1).

Jesus asked this question. *"What good is it if someone gains the whole world but loses his soul? Or what can anyone trade for his soul?"* Matthew 16:26.

It is important that, after baptism, we keep the example of Christ in mind. We must study our Heavenly Father's precious words in the Bible and constantly approach His "throne of grace" in prayer (Hebrews 4:14-15; 5:7,1 John 2:1).

In Psalm 119:97-99 we read, *"Lord, I really love your law! All day long I spend time thinking about it. Your commands make me wiser than my enemies, because your commands are always in my heart. I know more than all of my teachers do, because I spend time thinking about your covenant laws."*

2 Timothy 3:16-17 says, *"God has breathed life into all of Scripture. It is useful for teaching us what is true. It is useful for correcting our mistakes. It is useful for making our lives whole again. It is useful for training us to do what is right. By using Scripture, a man of God can be completely prepared to do every good thing."*

- To learn what is right
- To learn what is not right
- How to get it right, and
- Keeping it right.

It is part of God's plan with man that His people are ready; *"he will prepare a people who are ready for the Lord."* Luke 1:17.

63. One Final Word.

The time is short. Our world today stands on the verge of a mighty change. This is your opportunity! *"Now is the day he saves"* 2 Corinthians 6:2.

Only the present is ours. The past has gone, and the future has not come yet. *"What is your life? It is a mist that appears for a little while. Then it disappears."* James 4:14.

Then again, *"Don't brag about tomorrow. You don't know what a day will bring."* Proverbs 27:1. Be wise. God gave life to you for a time - and for a purpose. Make full use of it while you have it. Use it as a stepping-stone to greater things. It can lead to a joyful everlasting life.

"He says, 'When I showed you my favour, I heard you. On the day I saved you, I helped you.' I tell you, now is the time God shows his favour. Now is the day he saves." 2 Corinthians 6:2.

Never forget that the sun will go down at last on your day of opportunity.

"Now is the day he saves" 2 Corinthians 6:2.

Then, *"Listen to his voice today."* Hebrews 3:7. (See also Psalm 95:7, Luke 9:35).

"Turn to the LORD before it's too late. Call out to him while he's still ready to help you." Isaiah 55:6.

Now is the time!

ផែនការរបស់ព្រះជាមួយមនុស្ស

ផ្អែកលើកូនសៀវភៅនិពន្ធដោយ ហារ៉ូដ រ៉ាយ

កែសំរួល និងផ្លាស់ប្តូរសំរាប់ការប្រើប្រាស់ក្នុងប្រទេសកម្ពុជា ដោយ ស្ទីវ និង លីន អាម ។
រាល់ការបកប្រែពីភាសា អង់គ្លេស ទៅភាសាខ្មែរ ដោយ ណាល់ សិទ្ធិ

គ្រប់កិច្ចការអំពីយើង និងលើសពីយើងនិយាយ

មានព្រះមួយអង្គ

នៅក្នុងផែនដីនិងសមុទ្រ និងផ្ទៃមេឃ យើងអាចឃើញការងារអស្ចារ្យរបស់ទ្រង់។ នៅក្នុងរបស់ទាំងអស់នោះ គឺជាច្បាប់ ផែនការ និងព្រះចេស្តា។

រាល់ផែនការទាំងអស់មានអ្នកបង្កើត រាល់អំណាចព្រះចេស្តា ទាំងអស់មកពី កន្លែងខ្លះ។ តារាវិថីដែលបញ្ចេញពន្លឺនៅលើមេឃរាល់យប់ថ្ងៃ បានឱ្យយើងដឹងពីព្រះចេស្តា ដែលបានបង្កើតពួកវា។ ព្រះអាទិត្យ ព្រះច័ន្ទ និងផ្កាយ និយាយទៅកាន់ បុរស និងស្ត្រីនៅគ្រប់ជាតិសាសន៍ ហើយប្រាប់ពួកគេពីព្រះដែលពោពេញដោយអនុភាពអស្ចារ្យ ពីប្រាជ្ញាទ្រង់ និង សេចក្តីស្រលាញ់ទ្រង់។ ចូរអានអំពីអ្វីដែលបាននិយាយអំពីរបស់ទាំងនេះដោយមនុស្សដែលរស់នៅយូរយាន មុនសម័យកាលយើង។ ទំនុកដំកើង ៨:៣-៤

កាលណាទូលបង្គំពិចារណាមើលផ្ទៃមេឃ ជាការដែលព្រះហស្តទ្រង់បានធ្វើ គឺទាំងខែ នឹងផ្កាយ ដែលទ្រង់បានប្រតិស្ឋានទុក នោះតើមនុស្សជាអ្វី ដែលទ្រង់នឹងរលឹកដល់គេ ហើយកូនមនុស្សផង ដែលទ្រង់ប្រោសដូច្នេះ?

ទំនុកដំកើង ៨:៣-៤ ទំនុកដំកើង ១៩:១-៦ យ៉ូប ៣៨:៣១-៣៣ អេសាយ ៤០:២៦។

ឥឡូវ មានព្រះមួយ យើងអាចនឹងប្រាកដច្បាស់ថា

មានព្រះពិតតែមួយគត់

កាលពីអតីតកាល មនុស្សបានថ្វាយបង្គំព្រះជាច្រើន។ ពួកគេបានបង្កើតរូបព្រះដោយខ្លួនគេផ្ទាល់ ដែលធ្វើពីឈើ និងថ្ម។ ព្រះទាំងនេះជាព្រះក្លែងក្លាយ។ ពួកគេមិនអាចមើល ឬស្តាប់ មិនអាចគិត ឬនិយាយ ឬមានអារម្មណ៍ (ទំនុកដំកើង ១១៥:៤-៨)។ ព្រះគម្ពីរបានឱ្យយើងស្គាល់ ព្រះពិតនិងមានព្រះជន្មរស់។ ទាំងនេះជាចំនុចមួយចំនួនដែលព្រះគម្ពីរប្រាប់យើងអំពីទ្រង់ :

ព្រះគឺតែមួយ។ ទ្រង់គ្មានអ្វីប្រៀបស្មើរ។ ទ្រង់ខ្ពស់លើសគ្រប់ទាំងអស់។
អេភេសូ ៤:៦ " មានព្រះតែ ១ គឺជាព្រះវរបិតានៃទាំងអស់ ដែលទ្រង់ខ្ពស់លើទាំងអស់ គង់នៅកណ្តាលទាំងអស់ ហើយសណ្ឋិតនៅក្នុងទាំងអស់ " (ចោទិយកថា ៦:៤ អេសាយ ៤៥:៥ ២២ កូរិនថូសទី១ ៨:៦ អេភេសូ ៤:៦)។
ព្រះគ្មានការចាប់ផ្តើម។ ទ្រង់បានគង់នៅគ្រប់ពេល ហើយអស់កល្បជានិច្ច។
ទំនុកដំកើង ៩០:១-២ " ឱព្រះអម្ចាស់អើយ ទ្រង់បានធ្វើជាទីអាស្រ័យនៃយើងខ្ញុំ នៅអស់ទាំង ដំណតមក គឺមុនដែលអស់ទាំងភ្នំបានកើតឡើង ក្នុងកាលដែលទ្រង់មិនទាន់បង្កើតផែនដី នឹងមនុស្សលោកនៅឡើយ ចាប់តាំងពីអស់កល្ប រៀងទៅដល់អស់កល្បជានិច្ច នោះគឺទ្រង់ហើយ ជាព្រះ "។ (អេសាយ ៤០:២៨ ធីម៉ូថេទី១ ១:១៧)។
ព្រះគង់នៅស្ថានសួគ៌។ តែដោយសារពះចេស្តាព្រះវិញ្ញាណរបស់ទ្រង់ ទ្រង់មានវត្តមានគ្រប់សទីកន្លែងទាំងអស់។ ទ្រង់ឋិតនៅគ្រប់ទីកន្លែង ដើម្បីមើល ស្តាប់ និងធ្វើ (ទំនុកដំកើង ១៣៩:១-១២ ម៉ាថាយ ៦:៩)។

ព្រះមានផែនការមួយ

ព្រះ បានបង្កើតផ្ទៃមេឃ និងផែនដី និងប្រទេសជាតិជាច្រើននៅលើផែនដី និងត្រួតត្រាលើកិច្ចការរបស់ពួកគេ។ ដានីយ៉ែល ៤:១៧ " .....មនុស្សដែលរស់នៅបានដឹងថា ព្រះដ៏ខ្ពស់បំផុតទ្រង់គ្រប់គ្រងលើរាជ្យរបស់មនុស្ស ក៏ប្រគល់ដល់អ្នកណាតាមព្រះហឫទ័យ ព្រមទាំងតាំងមនុស្សសណ្ដានទាបថោកបំផុតឡើង ឱ្យគ្រប់គ្រងផង" (លោកុប្បត្តិ ១:១ នេហេមា ៩:៦ កិច្ចការ ១៧:២៤-២៨) ។

ព្រះទ្រង់បានបង្កើតផែនដីដោយមានគោលបំណងមួយ ។ ទ្រង់បានប្រតិស្ឋានវាឡើងដោយបំពេញដោយមនុស្សដែលថ្វាយសិរីល្អដល់ព្រះនាមទ្រង់ ។ សភាពអាក្រក់នាពេលបច្ចុប្បន្នរបស់ពិភពលោកគឺដោយសារតែអំពើបាបរបស់មនុស្ស ។ ប៉ុន្តែ ផែនការរបស់ព្រះ ដែលទ្រង់បានចែងទុកតាំងពីយូលង់មកហើយ នឹងកើតមាននៅពេលចុងក្រោយ ។

ផែនដីនឹងត្រូវបំពេញដោយសិរីល្អរបស់ទ្រង់

ហាកបាគុក ២:១៤ " ដ្បិតមនុស្សនឹងស្គាល់ដល់សិរីល្អនៃព្រះយេហូវ៉ា នៅពេញលើផែនដី ដូចជាទឹកក៏នៅពេញសមុទ្រដែរ " (អេសាយ ១១:៩ អេសាយ ៤៥:១៨) ។

ព្រះ ជាព្រះនៃ**សេចក្ដីស្រលាញ់** ។ តាមពិត "ព្រះជាសេចក្ដីស្រលាញ់ " (យ៉ូហានទី១ ៤:៨) ។
ទ្រង់ប្រកបដោយ
យុត្តិធម៌ និងទៀងត្រង់ និងបរិសុទ្ធ មានព្រះទ័យមេត្តាករុណា និងទន់ទន់សន្ដោសជាបរិបូរ ។
ទ្រង់ចង់ឱ្យមនុស្សដូចអង្គទ្រង់ ។ ទ្រង់បានប្រាប់យើងថាអស់អ្នកណាដែលធ្វើតាមទ្រង់នឹងរស់នៅអស់កល្បជានិច្ច នៅក្នុងសិរីល្អ និងព្រះចេស្ដារបស់ទ្រង់ ។
និក្ខមនំ ៣៤:៦-៧ " ទ្រង់យាងកាត់នៅមុខលោក ម៉ូសេ ទាំងប្រកាស់ថា យេហូវ៉ា គឺយេហូវ៉ាដ៏ជាព្រះទ្រង់មានព្រះហឫទ័យមេត្តាករុណា ហើយទន់សន្ដោស ទ្រង់យឺតនឹងខ្ញាល់ ហើយមានសេចក្ដីសប្បុរស នឹងសេចក្ដីទៀងត្រង់ ជាបរិបូរ ។ ទ្រង់មានសេចក្ដីមេត្តាករុណាដល់មនុស្សទាំងពាន់ ក៏អត់ទោសចំពោះសេចក្ដីទុច្ចរិត សេចក្ដីរំលង នឹងអំពើបាប ប៉ុន្តែទ្រង់មិនរាប់មនុស្សមានទោស ទុកជាឥតទោសឡើយ ទ្រង់ធ្វើទោសចំពោះសេចក្ដីទុច្ចរិតរបស់ឪពុក ទៅដល់កូនចៅដល់៣ ហើយ ៤ ដំណផង ។"

(ចោទិយកថា ៣២:៤ ម៉ាថាយ :៤៨ ពេត្រុសទី២ ១:៤)

ព្រះ ទ្រង់បានបើកបង្ហាញឱ្យដឹងពីផែនការ និងមាគារបស់ទ្រង់នៅក្នុងព្រះគម្ពី ។ ព្រះគម្ពីជាសៀវភៅមួយ ដែលមនុស្សទាំងអស់គួរអាន ដោយសា.....

ព្រះគម្ពីរ ជា ព្រះបន្ទូលរបស់ ព្រះ

ព្រះគម្ពីកើតចេញមកពីទ្រង់ ។ ដូច្នេះហើយ ព្រះគម្ពីគឺពិតនៅគ្រប់ផ្នែកទាំងអស់ ហើយក៏មិនអាចថាមិនសំរេច នោះដែរ ។ ព្រះទ្រង់បានបញ្ចូលនៅក្នុងគំនិតរបស់មនុស្ស អ្វីដែលទ្រង់ចង់ឱ្យចង់ដឹងពីទ្រង់ ផែនការរបស់ទ្រង់សំរាប់យើង និងផែនដី ។ព្រះគម្ពីប្រាប់យើងពីអ្វីដែលព្រះបានធ្វើពីអតីតកាល និងអ្វីដែលទ្រង់ នឹងធ្វើនៅថ្ងៃខាងមុខ ដើម្បីនឹងសំរេចផែនការនេះ ។

ព្រះគម្ពីផ្តល់ឱ្យមនុស្សនូវក្រិតវិន័យរបស់ព្រះដើម្បីដឹកនាំជីវិតគេក្នុងជីវិតរស់នៅនេះ ដើម្បីនៅពេលខាងមុខ គេនឹងទទួលបានជីវិតដែលនៅអស់កល្បជានិច្ចវិញ (ធីម៉ូថេទី២ ៣:១៥-១៧) " ....*តាំងពីតូចមក អ្នកបានស្គាល់បទគម្ពីរទាំងប៉ុន្មាន ដែលអាចនឹងនាំឱ្យអ្នកមានប្រាជ្ញាដល់ទីសង្រ្គោះ ដែលបានដោយសារសេចក្តីជំនឿជឿដល់ព្រះគ្រីស្ទយេស៊ូវ ។ គ្រប់ទាំងបទគម្ពីរ គឺជាព្រះ ទ្រង់បានបញ្ចេញ ព្រះវិញ្ញាណ បណ្តាលឱ្យតែងទេ ក៏មានប្រយោជន៏សំរាប់ការបង្រៀន ការរំឭកឱ្យដឹងខ្លួន ការប្រដៅដំរង់ នឹងការបង្ហាត់ខាងសេចក្តីសុចរិត ដើម្បីឱ្យអ្នកសំណប់របស់ព្រះ បានគ្រប់លក្ខណ៏ ហើយមានគ្រប់ទាំងចំណេះ សំរាប់នឹងធ្វើការល្អគ្រប់មុខ*" ។ ប្រសិនបើ មនុស្សមិនអាន ព្រះគម្ពី គេដើរក្នុងសេចក្តីងងឹត ។ ស្តេចដេវីឌបាននិយាយនៅក្នុងសញ្ញាចាស់ថា ព្រះបន្ទូលទ្រង់ជាចង្កៀង បំភ្លឺជើងទូលបង្គំ ហើយជាពន្លឺបំភ្លឺ ផ្លូវទូលបង្គំ (ទំនុកដំកើង ១១៩:១០៥) ។

ដូចដែលយើងសរសេរនៅពេលនេះពីផែនការរបស់ព្រះជាមួយមនុស្ស យើងនឹងត្រលប់មើលម្តងហើយ ម្តងទៀតទៅព្រះបន្ទូលអស្ចារ្យរបស់ព្រះ ។ យើងសូមឱ្យអ្នករៀនជាមួយយើងនូវផ្នែកមួយចំនួន ដែលយើង បានដកស្រង់មក ។

ព្រះគម្ពីត្រូវបានរួមផ្សំដោយ ៦៦ សៀវភៅទាំងអស់ ។ ព្រះគម្ពីរមានន័យថា ជាការប្រមូលផ្តុំសៀវភៅ

ជាច្រើន ។ ព្រះគម្ពីរបានប្រាប់យើងពីរឿងរបស់បុរសម្នាក់ ។ នៅក្នុងសៀវភៅដំបូង បានប្រាប់យើងថា.........

ព្រះបង្កើតមនុស្សពីធូលីដី

មនុស្សត្រូវបានបង្កើតឡើងជា សភាវៈមានជីវិតរស់ នៅពេលព្រះផ្លុំខ្យល់ដង្ហើមទៅឱ្យគេ " ខ្យល់ដង្ហើមជីវិត " (លោកុប្បត្តិ ២:៧) ។ អ័ដាម ជាមនុស្សដំបូង និងអេវ៉ា ជាប្រពន្ធរបស់អ័ដាម ។ ព្រះបានហាមគេមិនឱ្យបរិភោគពីដើមឈើ១ដើម នៅក្នុងសួនអេដែន ។ ដើមឈើនោះ ហៅថា " ដើមសំរាប់ដឹងខុសត្រូវ " (លោកុប្បត្តិ ២:៩ ១៧) ។ ដោយការធ្វើបែបនេះ ព្រះបានធ្វើការសាកល្បងពួកគេ ។ ទ្រង់បានដាក់ពួកគេនៅក្នុងសួនអេដែនដើម្បីឱ្យត្រួតត្រាលើសួននោះ ហើយបានប្រាប់គេថា ពួកគេអាចបរិភោគផ្លែឈើពីគ្រប់ដើមបាន តែលើកលែងមួយ ។ ប្រសិនបើ ពួកគេបរិភោគផ្លែពីដើមនោះ គេប្រាកដជាស្លាប់ (លោកុប្បត្តិ ២:១៧) ។

សេចក្តីស្លាប់បណ្តាលមកពីអំពើបាប

វាជារឿងក្រៀមក្រំមួយ ។ ពួកគេត្រូវបានល្បួង ហើយពួកគេបានធ្លាក់ទៅក្នុងសេចក្តីល្បួង ។ ពួកគេធ្វើអំពើបាប ដំបូងគឺជាស្ត្រី ហើយបន្ទាប់មកទៀតគឺបុរស (លោកុប្បត្តិ ៣:៦ ធីម៉ូថេទី១ ២:១៤) ។ ព្រះរក្សាព្រះបន្ទូលរបស់ទ្រង ។ ទ្រង់មានបន្ទូលថា ឥឡូវគេត្រូវតែស្លាប់ (លោកុប្បត្តិ ៣:១៩) ហើយពួកគេស្លាប់ (លោកុប្បត្តិ ៥:៥) ។

បន្ទាប់ពីអ័ដាមបានធ្វើបាប ព្រះបានមានបន្ទូលទៅគាត់ថា អ័ដាម " ឯងបានកើតពីធូលីដី ហើយឯងក៏នឹងក្លាយជាធូលីដីវិញ " ។ ប៉ុន្តែពួកគេមិនបានស្លាប់ភ្លាមនោះទេ ។ ព្រះបានបណ្តេញគេចេញពីសួន ហើយធ្វើការចិញ្ចឹមជីវិតដោយលំបាក និងទុក្ខព្រួយ រហូតដល់ គេក្លាយជាធូលីដីវិញ ។

ពួកគេបានបង្កើតកូនចៅ ។ កូនចៅរបស់ពួកគេក៏ត្រូវស្លាប់ដែរ ហើយការស្លាប់នេះបន្តរហូតដល់

កូនចៅជំនាន់ក្រោយៗ ។ សេចក្តីស្លាប់ត្រួតត្រាលើទាំងអស់ ។ សម័យក្រោយមកពីជំនាន់អ័ដាម សាវកប៉ូល បានសរសេរថា :

" បាបចូលមកលោកកីយដោយសារមនុស្សតែម្នាក់ ហើយក៏មានសេចក្តីស្លាប់ចូលមកដែរ ដោយសារអំពើបាបនោះជាយ៉ាងណា នោះសេចក្តីស្លាប់បានឆ្លងរាលដាល ដល់មនុស្សគ្រប់គ្នាយ៉ាងនោះដែរ ដ្បិតគ្រប់គ្នាបានធ្វើបាបហើយ " (រ៉ូម ៥:១២) ។

ឥឡូវយើងសូមសួរថា : តើអ្វីជាសេចក្តីស្លាប់? អ្វីដែលមនុស្សគិតអំពីអំពើបាប មិនបានជួយយើងទាល់តែសោះ ។ មានតែព្រះគម្ពីទេ ដែលយើងត្រូវតែត្រលប់មកមើល ។ នៅពេលដែលយើងដឹងច្បាស់ថាថាតើអ្វីដែលជាអំពើបាបនោះ យើងអាចមើលឃើញពីទំហំនៃសេចក្តីត្រូវការរបស់មនុស្ស ។ ប៉ុន្តែ យើងក៏អាចឃើញទំហំនៃសេចក្តីស្រលាញ់របស់ព្រះចំពោះមនុស្ស ការជួបគ្នារវាងសេចក្តីត្រូវការរបស់មនុស្សនិងព្រះគុណរបស់ទ្រង់ ។

ឥឡូវព្រះគម្ពី (សាស្តា ៩:៥) ប្រាប់យើងដូច្នេះថា " មនុស្សរស់ គេដឹងថាខ្លួននឹងស្លាប់ ប៉ុន្តែ

មនុស្សស្លាប់ឥតដឹងអ្វីឡើយ "

នៅពេលមនុស្សកើតមក គេចាប់ផ្តើមរស់នៅ នៅពេលគេស្លាប់គេលែងមានជីវិត ។ នោះជាការពិតដ៏សាមញ្ញនិងងាយយល់នៅក្នុងព្រះគម្ពី ។ រាង្គកាយត្រលប់ទៅជាធូលីដីវិញ ដូចដែលព្រះបានមានបន្ទូល វិញ្ញាណ ឬដង្ហើមជីវិត នឹងត្រលប់ទៅឯព្រះវិញ ដែលទ្រង់បានប្រទានមកនោះ (សាស្តា ១២:៧) ។ មនុស្សរស់ដែលបានបង្កើតឡើងដោយធនុចទាំងពីនេះ នឹងលែងមានទៀតហើយ ។ ព្រះប្រទានឱ្យយើងនូវសេចក្តីសង្ឃឹមលើសពីសេចក្តីស្លាប់ ។

ព្រះចាត់បុត្រារបស់ទ្រង់មកសង្គ្រោះមនុស្ស......

ឱ្យរួចផុតពីសេចក្តីស្លាប់ ហើយប្រទានឱ្យគេនូវជីវិតអស់កល្បជានិច្ច ។ យ៉ូហាន ៣:*១៦* *" ដ្បិតទ្រង់ស្រលាញ់មនុស្សលោកដល់ម្លេះ បានជាទ្រង់ប្រទានព្រះរាជបុត្រាទ្រង់តែ១ ដើម្បីឱ្យអ្នកណាដែលជឿដល់ព្រះរាជបុត្រា*

នោះ មិនត្រូវវិនាសឡើយ គឺឱ្យមានជីវិតអស់កល្បជានិច្ចវិញ "។ នោះពិតប្រាកដណាស់ថា មនុស្ស ទទួលយក**ផ្លូវរបស់ទ្រង់** ។ ព្រះទ្រង់នឹងឱ្យគេប្រែចិត្ត និងត្រលប់មកឯទ្រង់វិញ។

ទ្រង់ប្រទានការអត់ទោស

អំពើបាប របស់ពួកគេ ប្រសិនបើពួកគេធ្វើតាម ។ អេសាយ ៥៥: ៦-៧ " *ចូរស្វែងរកព្រះយេហូវ៉ា ក្នុងកាលដែលអាចនឹងរកទ្រង់ឃើញ ហើយអំពាវនាវដល់ទ្រង់ ក្នុងកាលដែលទ្រង់គង់នៅជិតចុះ ត្រូវឱ្យមនុស្សអាក្រក់ បោះបង់ចោលផ្លូវរបស់ខ្លួនដែរ រួចឱ្យគេត្រលប់មកឯព្រះយេហូវ៉ាវិញ នោះទ្រង់នឹងអាណិងមេត្តាដល់គេ គឺឱ្យវិលមកឯព្រះនៃយើងរាល់គ្នា ដ្បិតទ្រង់នឹងអត់ទោសឱ្យជាបរិបូរ* " ។ (អាចមើល កិច្ចការ ២:៣៨ ផងដែរ) ។

ព្រះបង្ហាញសេចក្តីស្រលាញ់របស់ទ្រង់ចំពោះពិភពលោក។ ទ្រង់ចាត់ព្រះយេស៊ូវមកដឹកនាំមនុស្សឱ្យត្រលប់មកឯទ្រង់វិញ ដូចជាអ្នកគង្វាល ដែលនាំយកចៀមដែលបវរអេង្វងត្រលប់មកវិញ (ពេត្រុសទី១ ២:២៥) ។ ព្រះយេស៊ូវមានបន្ទូលថា ខ្ញុំជាអ្នកគង្វាលល្អ ជាអ្នកដែលស៊ូប្តូរជីវិតជំនួសចៀម (យ៉ូហាន ១០:១១) ។

ព្រះយេស៊ូវជាព្រះរាជបុត្រានៃព្រះ

ត្រលប់ទៅមើលសួនអេដែន ព្រះបានមានបន្ទូលថា បន្ទាប់ពី អ័រដាម និង អេវ៉ាបានធ្វើបាបទាស់នឹងព្រះ នោះពូជ នាងនឹងកិនក្បាលពស់ (លោកុប្បត្តិ ៣:១៥) ។ អេវ៉ា បានស្តាប់សត្វពស់ : " *អ្នកមិនស្លាបជាមែនទេ*" (លោកុប្បត្តិ ៣:៤) ។ ដូច្នេះសត្វពស់ជាសត្វ តំណាងឱ្យ**អំពើបាប** ។

កិនក្បាលពស់

មានន័យថា ការបញ្ចប់ និងការកាត់ទោសអំពើបាប សំរាប់អ្នកដែលដើរតាម អង្គព្រះយេស៊ូវគ្រីស្ទ។

តើនរណាជាពូជរបស់ស្ត្រី ? នោះគឺជាអង្គព្រះយ៉េស៊ូវគ្រីស្ទ (កិច្ចការ ២:២២) ជាអ្នកដែល ព្រះបានមានបន្ទូលថា " នេះជាកូនស្ងួនភ្ងារបស់ អញ ជាទីពេញចិត្តអញណាស់" (ម៉ាថាយ ៣:១៧) ។ ព្រះសព្វព្រហឬទ័យនឹងព្រះយ៉េស៊ូវគ្រីស្ទ ពីព្រោះ ព្រះយ៉េស៊ូវតែងតែធ្វើការ ដែលគាប់ដល់ព្រះហឬទ័យ ព្រះវបិតាទ្រង់ (យ៉ូហាន ៨:២៩) ។

នៅក្នុងគម្ពីកាឡាទី ៤:៤ យើងអាន " តែលុះវេលាកំនត់បានមកដល់ នោះព្រះទ្រង់បានចាត់ព្រះរាជបុត្រាទ្រង់ ឱ្យមកចាប់កំនើតនឹងស្ត្រី" ព្រះយេស៊ូវគឺជា.....

ពូជរបស់ស្ត្រី

ដោយសារមនុស្សប្រុសមិនមែនជាបិតារបស់ព្រះយេស៊ូវ ទោះជាស្ត្រីជាមាតារបស់ទ្រង់។ បិតារបស់ទ្រង់គឺជាព្រះ។ ព្រះគម្ពីបានប្រាប់យើងថា ព្រះបានជ្រើសរើសនាងម៉ារី ជាម្តាយរបស់ បុត្រារបស់ទ្រង់។ ម៉ារីត្រូវបានប៉ះពាល់ដោយព្រះវិញ្ញាណអស្ចារ្យរបស់ព្រះ។ ទេវតារបស់ព្រះនិយាយទៅកាន់នាងថា *" ព្រះវិញ្ញាណបរិសុទ្ធនឹងយាងមកសណ្ឋិតលើនាង.........ហេតុដូច្នេះ បុត្របរិសុទ្ធដែលនឹងប្រសូតមកនោះ ត្រូវហៅថាជាព្រះរាជបុត្រានៃព្រះ"* (លូកា ១:៣៥)។

ព្រះវិញ្ញាណបរិសុទ្ធ......

ជាព្រះចេស្តារបស់ព្រះ។ "បរិសុទ្ធ " មានន័យថា បែកចេញ ឬផ្តាច់ចេញ។
តាមរយៈព្រះចេស្តានោះ ព្រះបានឱ្យកំនើងដល់ព្រះយេស៊ូវ ហើបន្ទាប់ទៀតនៅក្នុងជីវិតព្រះយេស៊ូវ នៅពេលទ្រង់បានជ្រមុជទឹកដោយលោក យ៉ូហាន នៅទន្លេយ័ដាន់ ព្រះទ្រង់បានប្រទានព្រះចេស្តាឱ្យព្រះយេស៊ូវ។ ព្រះបានបង្ហាញអង្គទ្រង់នៅក្នុងបុត្រារបស់ទ្រង់ មានព្រះបន្ទូលទៅកាន់អីស្រាអែលតាមរយៈព្រះយេស៊ូវគ្រីស្ទ ហើយធ្វើការងារអស្ចារ្យ (ការអស្ចារ្យ) ដែលយើងអាចអានពីជីវិតព្រះយេស៊ូវ (ម៉ាថាយ ៣:១៦ យ៉ូហាន ៣:៣៤ យ៉ូហាន៥:១៩ យ៉ូហាន ៨:២៨ យ៉ូហាន១៤:១០ កិច្ចការ ១០:៣៨)។

" បុត្រាបរិសុទ្ធនោះ" ដែលប្រសូត្រពីម៉ារី មានឈ្មោះ មុនពេលដែលទ្រង់បានប្រសូត្រទៀត។ នោះគឺជាទេវតារបស់ព្រះទៀតដែលបានមានបន្ទូលថា " នាងត្រូវថ្វាយព្រះនាមថា យេស៊ូវ ព្រោះបុត្រនោះនឹងជួយសង្គ្រោះរាស្ត្រទ្រង់ឱ្យរួចពីបាប "(ម៉ាថាយ ១ :២១)។

ឈ្មោះថា យេស៊ូវ មានន័យថា ព្រះសង្គ្រោះ ។តើព្រះយេស៊ូវគ្រីស្ទ សង្គ្រោះ យើង

ពីអំពើ បាប ដោយរបៀបណា? ព្រះគម្ពីចែងថា " ដោយសារជំនឿលើឈាមទ្រង់ " (រ៉ូម ៣:២៥) ។ នៅក្នុងសៀវភៅដដែលក៏និយាយថា : ដោយរបៀបណា

មនុស្សសុចរិតនឹងរស់នៅដោយសារជំនឿ (ហាបាគុ ២:៤ ហេព្រើ ១០ :៣៨)

ជំនឿ គឺជាចិត្តដែលជឿពីការដែលមើលមិនឃើញ ដោយភ្នែកយើងផ្ទាល់ ។ ព្រះគម្ពីបានបញ្ជាក់យ៉ាងច្បាស់ថា បើឥតមានជំនឿទេ នោះមិនអាចគាប់ព្រះហឫទ័យព្រះបានឡើយ ។ ហេព្រើ ១១: ១ , ៦

" *រីឯសេចក្តីជំនឿ នោះគឺជាចិត្តដែលដឹងជាក់ថា នឹងបានដូចសង្ឃឹម ជាសំគាល់ពីការដែលមើលមិនឃើញ... បើឥតមានជំនឿទេ នោះមិនអាចគាប់ព្រះហឫទ័យព្រះបានឡើយ ដ្បិតអ្នកណាដែលចូលទៅឯព្រះនោះត្រូវតែជឿថា មានព្រះមែន ហើយថា ទ្រង់ប្រទានរង្វាន់ ដល់អស់អ្នកណាដែលស្វែងរកទ្រង់ ។* "

ព្រះឱ្យមនុស្សជឿលើព្រះយេស៊ូវគ្រីស្ទ ជឿលើអ្វីដែលបានធ្វើតាមរយៈទ្រង់ និងលើអ្វីដែលនឹងធ្វើតាមរយៈទ្រង់ នៅពេលអនាគត ។ យ៉ូហាន ៣:១៦ " *ដ្បិតទ្រង់ស្រលាញ់ មនុស្សលោកដល់ម្លេះ បានជាទ្រង់ប្រទានព្រះរាជបុត្រាទ្រង់តែ១ ដើម្បីឱ្យអ្នកណាដែលជឿដល់ព្រះរាជបុត្រា នោះ មិនត្រូវវិនាសឡើយ គឺឱ្យមានជីវិតអស់កល្បជានិច្ចវិញ* "។ (រ៉ូម ១០:៩-១១) ។

អំពើបាប និងសេចក្តីស្លាប់គ្មានអំណាចលើអ្នកដែលជឿទេ ។ ធីម៉ូថេទី២ ១:១០ " ....*ព្រះយេស៊ូវគ្រីស្ទ ជាព្រះអង្គសង្គ្រោះនៃយើង ទ្រង់លេចមក ដែលទ្រង់បានបំផ្លាញសេចក្តីស្លាប់ ហើយបានយកជីវិត និងសេចក្តីមិនចេះស្លាប់ មកដាក់នៅពន្លឺ ដោយសារដំណឹងល្អ* ។ ព្រះយេស៊ូវជាផលផ្លែដំបូង ពីការងារសង្គ្រោះរបស់ព្រះ (កូរិនថូសទី១ ១៥:២៣) ។ ព្រះយេស៊ូវឥឡូវអាចសង្គ្រោះ បានទាំងស្រុងដល់មនុស្សទាំងអស់ ដែលចូលចំពោះព្រះតាមរយៈទ្រង់ ដ្បិតទ្រង់មានព្រះជន្មរស់នៅជានិច្ច ដើម្បីនឹងជួយអង្វរជំនួសគេ" (ហេព្រើ ៧:២៥) ហើយមនុស្សមិនអាចចូលចំពោះព្រះតាមផ្លូវណាផ្សេង ទៀតបានទេ ។ បុត្រានៃព្រះនិយាយពីអង្គទ្រង់ថា : " ខ្ញុំគឺជា .....

ផ្លូវ សេចក្តីពិត ហើយជាជីវិត...

......បើមិនមកតាមខ្ញុំ នោះគ្មាននរណាទៅឯព្រះវបិតាបានឡើយ" យ៉ូហាន ១៤:៦ ។ ព្រះយេស៊ូវមានបន្ទូលដោយសេចក្តីស្រលាញ់ថា " អស់អ្នកដែលនឿយព្រួយ ហើយផ្ទុកធ្ងន់អើយ ចូរមកឯខ្ញុំ ខ្ញុំនឹងឱ្យអ្នករាល់គ្នាសំរាក ចូរទទួលនឹមខ្ញុំ ហើយរៀននឹងខ្ញុំចុះ ដ្បិតខ្ញុំស្លូត ហើយមានចិត្តសុភាព នោះអ្នករាល់គ្នានឹងបានសេចក្តីសំរាកដល់ព្រលឹង " ម៉ាថាយ ១១:២៨-២៩ ។

ព្រះយេស៊ូវមានលក្ខណៈដូចជាយើង

ទោះជាព្រះយេស៊ូវជាព្រះបុត្រានៃព្រះពីកំណើត ព្រះយេស៊ូវគឺ " បានដូចជាបងប្អូនទ្រង់គ្រប់ជំពូកដែរ " ហេព្រើរ ២:១៧។ " ទ្រង់រួមចំណែកជាសាច់ឈាមដូច្នោះដែរ " ដូចអ្នកដែលទ្រង់នឹងសង្គ្រោះ (ហេព្រើរ ២:១៤) ។ សាវកប៉ូល ក៏បានប្រាប់យើងនៅក្នុង រ៉ូម ៨:៣ ថាព្រះ"បានចាត់ព្រះរាជបុត្រាទ្រង់ឱ្យមកមានរូបអង្គ បែបដូចជាសាច់ឈាម ដែលតែងតែមានបាប " ។ នៅក្នុង កូរិនថូសទី១ ១៥:៤៥ យើងអានពីព្រះយេស៊ូវថាជា " អាដាមចុងក្រោយ " ។ យើងឃើញថា អាដាមដំបូងបានធ្វើបាប ហើយដោយសារគាត់ធ្វើបាប គាត់ស្លាប់។ អាដាមចុងក្រោយ ទោះបីជាទ្រង់ត្រូវល្បួង តែមិនដែលធ្វើបាប។ ទ្រង់មិនដែលឱ្យផ្លូវទៅ.........

អារក្ស

អារក្សនៅក្នុងព្រះគម្ពី ជាឈ្មោះសំរាប់អ្វី ដែលបណ្តាលឱ្យមានអំពើបាប។ ព្រះមានបន្ទូលប្រាប់យើងថា " តែដែលគ្រប់គ្នាកើមានសេចក្តីល្បួង នោះគឺដោយសារតែសេចក្តីប៉ងប្រាថ្នារបស់ខ្លួននាំប្រទាញ ហើយលួងលោមទេ" យ៉ាកុប ១:១៤។ យើងដឹងការនេះពីអ្វីដែលក្នុងខ្លួនយើងមានអារម្មណ៏។

ឥឡូវព្រះយេស៊ូវ ប្រាប់យើងថា" ទ្រង់បានត្រូវសេចកីល្បួងគ្រប់យ៉ាង ដូចជាយើងរាលគ្នាដែរ តែឥតធ្វើបាបឡើយ" ហេព្រើ ៤ :១៥។ ហើយ ពូជនៃសត្វពស់ (សាសន៏យូដា និងសាសន៏ដ៏ទៃ រួមដោយអំពើបាប) ដំទ្រង់នឹងដែកគោលលើឈើឆ្កាង។ នោះជាបំណងព្រះហឬទ័យរបស់ព្រះដែលព្រះរាជបុត្រារបស់ទ្រង់ គួរតែស្លាប់ក្នុងរបៀបបែបនោះ (កិច្ចការ ២:២៣) ។ ព្រះយេស៊ូវគ្រីស្ទស្តាប់តាមបំណង់ព្រះហឬទ័យព្រះវបិតា ទោះបីការស្លាប់ដោយឃោឃៅលើឈើឆ្កាង (លូកា ២២:៤២ ភីលីប ២:៨) ។ នៅក្នុងការបង្ហូឈាមរបស់ទ្រង់ ជីវិតរបស់ទ្រង់ត្រូវបានបូជាសំរាប់អំពើបាបអ្នកដ៏ទៃ (អេសាយ ៥៣:៥ ហេព្រើ ៩:២២ ពេត្រុសទី១ ៣:១៨) ។ ពេត្រុសទី១ ២:២៤ " ទ្រង់បានផ្ទុកអំពើបាបរបស់យើងរាល់គ្នា នៅលើរូបអង្គទ្រង់ ជាប់លើឈើឈ្កាង ដើម្បីឱ្យយើងបានរស់ខាងឯសេចក្តីសុច្ចរិត ដោយបានស្លាប់ខាងឯអំពើបាបហើយ គឺដោយស្នាមជាំរបស់ទ្រង់ ដែលអ្នករាល់គ្នាបានជា" ។ ទ្រង់បានប្រគល់ជីវិតមានតំលៃរបស់ទ្រង់ ដើម្បីមនុស្សមានអំពើបាបអាចរស់នៅតាមរយៈទ្រង់។ នេះជាសេចក្តីស្រលាញ់ដែលជ្រាលជ្រៅ និងអស្ចារ្យបំផុត។ ព្រះយេស៊ូវមានបន្ទូលដោយអង្គទ្រង់ថា " គ្មានអ្នកណាមានសេចក្តីស្រលាញ់ធំជាងនេះ គឺដែលអ្នកណានឹងប្តូរ

ជីវិត ជំនួសពួកសំឡាញ់ខ្លួននោះទេ" យ៉ូហាន ១៥:១៣។ មិនត្រឹមតែជាសេចក្តីរបស់ព្រះរាជបុត្រា នោះទេ សេចក្តីស្រលាញ់របស់ព្រះវបិតាក៏បានបង្ហាញដែរ ហើយទ្រង់មិនសំចៃទុកព្រះរាជបុត្រាទ្រង់បង្កើត គឺបានបញ្ជូនទ្រង់ទៅជំនួសយើងរាល់គ្នា (រ៉ូម ៨:៣២)។ ប៉ូល និយាយនៅក្នុង រ៉ូម ៥:៨ " តែឯព្រះ ទ្រង់សំដែងសេចក្តីស្រលាញ់របស់ទ្រង់ ដល់យើងរាល់គ្នា : នោះនៅក្នុងការដែលយើងនៅមានបាប នៅឡើយផង....

ព្រះគ្រីស្ទសុគតជំនួសយើង

ប៉ុន្តែ នេះមិនមានន័យថាព្រះបានដាក់ទណ្ឌកម្មព្រះរាជបុត្រារបស់ទ្រង់ចំពោះអំពើបាបរបស់អ្នកដ៏ទៃនោះទេ។ ព្រះលើកលែងទោសឱ្យមនុស្ស ប្រសិនបើពួកគេស្លាប់ជាមួយព្រះគ្រីស្ទតាមរយៈពិធីជ្រមុជទឹក។ រ៉ូម ៦:៣-៤ " តើអ្នករាល់គ្នាមិនដឹងទេឬអីថា យើងរាល់គ្នាទាំងប៉ុន្មាន ដែលបានទទួលបុណ្យជ្រមុជ ក្នុងព្រះយេស៊ូវគ្រីស្ទ នោះគឺបានទទួលជ្រមុជក្នុងសេចក្តីសុគតនៃទ្រង់ដែរ ដូច្នេះយើងបានត្រូវកប់ជាមួយនឹងទ្រង់ហើយ ដោយទទួលជ្រមុជក្នុងសេចក្តីស្លាប់ ដើម្បីឱ្យយើងបានដើរក្នុងជីវិតបែបថ្មី ដូចជាព្រះគ្រីស្ទបានរួចពីស្លាប់ឡើង វិញ ដោយសារសិរីល្អនៃព្រះវបិតាដែរ។ " (រ៉ូម ៣:២៥ កូល៉ុស ១:១៤)។ យើងនឹងក្រលេកមើលលំអិត បន្ថែមទៀតពេលក្រោយទៀត នៅក្នុងសៀវភៅនេះ។

ទោះជាទ្រង់បានស្លាប់ ហើយត្រូវគេយកទៅបញ្ចុះ តែព្រះយេស៊ូវមិនបានក្លាយជាធូលីដី ដូចជាអាដាម ដំបូងទេ។ ព្រះបានប្រាប់អ្នកធ្វើអំពើបាបមុនដំបូងគេថា " អ្នកឯងនឹងត្រលប់ក្លាយជាធូលីដីវិញ " ។ ការនេះមិនកើតឡើងចំពោះព្រះគ្រីស្ទ ជាអ្នកដែលគ្មានបាបសោះ។ ព្រះដែលសុច្ចរិត

មិនអនុញ្ញាតឱ្យព្រះយេស៊ូវក្លាយជាធូលីដីទេ ព្រោះទ្រង់ " គ្មានអំពើបាប....

ព្រះបានប្រោសឱ្យព្រះយេស៊ូវរស់ពីស្លាប់វិញ.....

......ហើយផ្តល់សិរីល្អឱ្យទ្រង់ " កិច្ចការ ២:៣២-៣៣ " ព្រះបានប្រោសឱ្យព្រះយេស៊ូវមានព្រះជនរស់ឡើង វិញ ហើយពួកយើងនេះជាទីបន្ទាល់ពីទ្រង់ទាំងអស់គ្នា ដូច្នេះ ដែលទ្រង់បានដំកើងឡើង ដោយសារព្រះហស្ត ស្តាំនៃព្រះ ហើយបានទទួលសេចក្តីសន្យា គឺជាព្រះវិញ្ញាណបរិសុទ្ធពីព្រះវបិតា នោះទ្រង់បានចាក់សេចក្តីនោះ

មក ដែលអ្នករាល់គ្នាកំពុងតែមើលហើយស្តាប់ " ។ រយៈពេលយូរមុនពេល ព្រះយេស៊ូវប្រសូត នោះមានការ កត់ត្រាពីព្រះយេស៊ូវ " ដ្បិតទ្រង់មិនទុកឱ្យព្រលឹងទូលបង្គំ នៅក្នុងស្ថានឃុំព្រលឹងមនុស្សស្លាប់ទេ ក៏មិនព្រម ឱ្យអ្នកបរិសុទ្ធរបស់ទ្រង់ឃើញសេចក្តីពុករលួយដែរ " ទំនុកដំកើង ១៦:១០ កិច្ចការ ២:២៧ ។ ព្រះវបិតាបាន ប្រទានជីវិតបុត្រាសុច្ចរិតរបស់ទ្រង់សំរាប់យើង ហើយប្រោសទ្រង់ ឱ្យនៅខាងព្រះហស្តស្តាំនៃព្រះនៅ នគរស្ថានសួគ៌ (ទំនុកដំកើង ១១០:១) ។ ព្រះយេស៊ូវ ឥឡូវគង់នៅទីនោះ ជាសំដេចសង្ឃខ្ពស់បំផុត នៅក្នុងដំណាក់របស់ទ្រង់ ។ ដំណាក់របស់ទ្រង់ ត្រូវបានបង្កើតឡើងដោយ អ្នកដែលដើរតាមទ្រង់ ដោយជំនឿ និងសេចក្តីពិត (ហេព្រើ ៣:៦) ។ នៅពេលឆាប់ខាងមុខ យើងនឹងឃើញពីរបៀបដែលយើងប្រកាន់ខ្ជាប់ ព្រះនាមទ្រង់ ហើយដូច្នេះហើយយើងនឹងរួមមកតែមួយជាមួយទ្រង់ ដើម្បីឱ្យយើងអាចរួមចំនែកនៅក្នុង ជ័យជំនះរបស់ទ្រង់ ។

ព្រះយេស៊ូវនឹងយាងមកម្តងទៀត

ព្រះយេស៊ូវបានត្រលប់ទៅស្ថានសួគ៌ បន្ទាប់ពីទ្រង់បានរស់ពីសុគតវិញបាន ៦ សប្តាហ៍ ។ ទេវតាបានប្រាប់ អ្នកដែលបាននៅជាមួយទ្រង់ " ព្រះយេស៊ូវ...នឹងយាងមកវិញ តាមបែបដដែល ដូចជាអករាល់គ្នាបានឃើញ ទ្រង់ទៅស្ថានសួគ៌ " កិច្ចការ ១:១១ ។ ចាប់តាំងពីពេលនោះមក សាវ័ករបស់ទ្រង់បានបង្រៀនថា ទ្រង់នឹង ត្រលប់មកផែនដីដើម្បីឱ្យផែនការរបស់ព្រះបានសំរេច ។ កិច្ចការ ៣:២០-២១ " ហើយទ្រង់បានចាត់ព្រះអង្គ នោះដែលបានតំរូវទុកជាមុន មកឯអ្នករាល់គ្នា គឺជាព្រះយេស៊ូវគ្រីស្ទ ដែលស្ថានសួគ៌ត្រូវទទួល ដរាបដល់គ្រា តាំងរបស់ទាំងអស់ឡើងវិញ ដែលព្រះបានមានបន្ទូលប្រាប់ពីគ្រានោះ ដោយសារមាត់នៃពួកហោរាបរិសុទ្ធ របស់ទ្រង់ តាំងពីបុរាណមក ។ " (កូរិនថូសទី១ ១៥:២៣ ២៥ ថែស្សាឡូនិចទី១ ១:១០) ។

មនុស្សស្លាប់នឹងត្រូវប្រោសឱ្យរស់ឡើងវិញ

ការងារដំបូងរបស់ព្រះយេស៊ូវ នៅពេលទ្រង់យាងត្រលប់មក ជាស្តេចដើម្បីនឹងប្រោសអ្នកដែលស្លាប់ ពីការដេកលក់របស់គេ ។ ដានីយ៉ែល ១២:២ " ហើយពួកអ្នកដែលដេកលក់នៅក្នុងធូលីដី នឹងភ្ញាក់ឡើងវិញ ជាច្រើន គឺខ្លះឱ្យបានជីវិតរស់នៅអស់កល្បជានិច្ច នឹងខ្លះឱ្យបានសេចក្តីអាម៉ាស់ខ្មាស់ ហើយឱ្យបានជាទីខ្ពើម ឆ្អើម នៅអស់កល្បជានិច្ចវិញ " ។ (យ៉ូហាន ៦:៤០ កិច្ចការ ២៤:១៥ កូរិនថូសទី១ ១៥:៥២

ថែស្សាឡូនិចទី១ ៤:១៦) ។ ប៉ុន្តែ មិនមែនគ្រប់គ្នា នឹងរស់ពីស្លាប់ឡើងវិញនោះទេ ។ ព្រះគម្ពីបង្រៀនយើង ថា អ្នកមិនដែលស្គាល់ព្រះ និងផែនការរបស់ទ្រង់ នឹងចិតនៅក្នុងផ្នូរ ។ ទំនុកដំកើង ៤៩:១៤ និង ២០ " ដូចជាហ្វូងសត្វដែលគំរង់នៅឯទីស្លាប់ សេចក្ដីស្លាប់នឹងស៊ីគេ.....មនុស្សដែលមានកេរ្តិ៍ឈ្មោះ តែឥតមានយោបល់ នោះធៀបដូចជាសត្វតិរច្ឆាន ដែលវិនាសទៅនោះឯង ។ " (សុភាសិត ២១:១៦) ។ ម្យ៉ាងវិញទៀត ប្រសិនបើមនុស្សម្នាក់ស្គាល់ពីបំណងព្រះហឬទ័យព្រះ តែបដិសេដ្ឋមិនគោរពតាម នោះគេនឹងត្រូវទទួលអំពើបាបរបស់គេ ។ យ៉ាកុប ៤:១៧ " ដូច្នេះ ឯអ្នកណាដែលចេះធ្វើល្អ តែមិនធ្វើសោះ នោះរាប់ជាបាបដល់អ្នកនោះវិញ ។ "

មនុស្សស្លាប់ នឹងត្រូវរស់ឡើងវិញ ដើម្បីនឹងត្រូវជំនុំជំរះ និងទទួលរង្វាន់ ទៅតាមការងាររបស់គេ ។ លោកប៉ូល និយាយថា " ដ្បិតយើងត្រូវ (គាត់បានសរសេរទៅកាន់មនុស្សដែលស្គាល់បំណងព្រះហឬទ័យរបស់ព្រះ) ទៅនៅមុខ........

ទីជំនុំជំរះរបស់ព្រះគ្រីស្ទ........

.......ដើម្បីឱ្យគ្រប់គ្នាបានទទួលតាមការដែលបានធ្វើ ពីកាលនៅក្នុងរូបកាយរៀងខ្លួន ទោះល្អ ឬអាក្រក់ក្តី " កូរិនថូសទី២ ៥:១០ ។ ព្រះបានតាំងព្រះយេស៊ូវគ្រីស្ទ ឱ្យជំនុំជំរះដល់ទាំងមនុស្សរស់ និងមនុស្សស្លាប់ផង ។ កិច្ចការ ១០:៤២ " ទ្រង់ផ្តាំមកយើងរាល់គ្នា ឱ្យប្រកាសប្រាប់ដល់បណ្តាជនទាំងឡាយ ហើយឱ្យធ្វើបន្ទាល់សព្វគ្រប់ថា គឺព្រះអង្គនេះហើយ ដែលព្រះបានតាំងឡើង ឱ្យជុំនុំជំរះដល់ទាំងមនុស្សរស់ផង និងមនុស្សស្លាប់ផង ។ " (កិច្ចការ ១៧:៣១ ធីម៉ូថេទី២ ៤:១) ។ ការជំនុំជំរះ នឹងញែកមនុស្សអាក្រក់ពីមនុស្សសុច្ចរិត ។

មនុស្សអាក្រក់នឹងត្រូវវិនាស

ព្រះគម្ពីបានបង្ហាញយើងថា មនុស្សអាក្រក់នឹងមិនរស់នៅអស់កល្បជានិច្ចទេ ។ ពួកគេនឹងត្រូវបានបំផ្លាញបន្ទាប់ពីត្រូវបានដាក់ទណ្ឌកម្មតាមតែចៅក្រមនឹងសំរេច ។ ថែស្សាឡូនិចទី២ ១:៧-៩ ".....ក្នុងកាលដែលព្រះអម្ចាស់យេស៊ូវ ទ្រង់លេចមកពីស្ថានសួគ ជាមួយនឹងទេវតានៃព្រះចេស្តាទ្រង់ នៅក្នុងអណ្តាតភ្លើងទាំងសងសឹកនឹងពួកអ្នកដែលមិនស្គាល់ព្រះ ហើយនឹងពួកអ្នកដែលមិនស្តាប់តាមដំណឹងល្អ ពីព្រះយេស៊ូវគ្រីស្ទ

គេនឹងរងទុក្ខទោស ជាសេចក្តីហិនវិនាសអស់កល្បជានិច្ច ឃ្លាតពីព្រះភក្រ្តនៃព្រះអម្ចាស់ ហើយពីសិរីល្អនៃព្រះចេស្តាទ្រង់" (ទំនុកដំកើង ៣៧:៩-១០ និង ២០ មីកា ៤:១) ។ តែដោយសារ "ឈ្នួលនៃអំពើបាប ជាសេចក្តីស្លាប់ នោះជាការពិតផងដែរថា.........

អំណោយទានរបស់ព្រះនោះជាជីវិតអស់កល្បជានិច្ច......

....ដោយព្រះយេស៊ូវ ជាព្រះអម្ចាស់នៃយើងរាល់គ្នា" រ៉ូម ៦:២៣។ នេះពិតជាសេចក្តីដ៏អស្ចារ្យបំផុតនៅក្នុងព្រះគម្ពី។ ជីវិតអស់កល្បជានិច្ចមិនមែនជាអ្វីដែលយើងអាចរកបានដោយខ្លួនឯងដូចប្រាក់កំរៃទេ។ សេចក្តីស្លាប់ ជាឈ្នួលរបស់អ្នកធ្វើបាប តែជីវិតអស់កល្បជានិច្ច យើងអាចទទួលបានដោយព្រះគុណរបស់ព្រះ។ ព្រះយេស៊ូវ នឹងប្រទានអំណោយនេះទៅឱ្យមនុស្សគ្រប់គ្នា ដែលទ្រង់ទទួលនៅពេលទ្រង់យាងមកម្តងទៀត។ យ៉ូហាន ១០:២៧-២៨ (ព្រះយេស៊ូវមានបន្ទូល) "ចៀមខ្ញុំទាំងប៉ុន្មានវាស្តាប់ខ្ញុំ ហើយមកតាម ខ្ញុំក៏ស្គាល់វាដែរ ខ្ញុំឱ្យជីវិតអស់កល្បជានិច្ចដល់វា វាមិនត្រូវវិនាសនៅអស់កល្បរៀងទៅ ក៏គ្មានអ្នកណាឆក់វាពីដៃខ្ញុំបានដែរ។ "(រ៉ូម ២:៦-៧ កូរិនថូសទី១ ១៥:៥៣-៥៤ យ៉ូហានទី១ ២:២៥)។

ជំនឿ និងពិធីជ្រមុជទឹក នាំឲពីគេសំខាន់

ដើម្បីទទួលបានជីវិតអស់កល្បជានិច្ច។ ព្រះយេស៊ូវមានបន្ទូលថា " អ្នកណាដែលជឿ ហើយទទួលបុណ្យជ្រមុជទឹក នោះនឹងបានសង្រោះ "(ម៉ាកុស ១៦:១៦)។ យើងត្រូវតែជឿ អ្វីដែលព្រះយេស៊ូវបង្រៀន និង ដំណឹងល្អ ពីនគរព្រះ។

ព្រះយេស៊ូវបានបង្រៀននៅក្នុងគម្ពីលូកា៨:១ " ក្រោយនោះមកទៀត ទ្រង់យាងទៅប្រដៅគ្រប់ក្រុង គ្រប់ភូមិ ព្រមទាំងប្រាប់ដំណឹងល្អពីនគរព្រះ។ អាចមើលនៅក្នុង ម៉ាថាយ ៤:២៣ និង ម៉ាកុស ១:១៤។ នោះជានគរព្រះ។ ព្រះយេស៊ូវបានប្រាប់សាវក " ទៅគ្រប់ទាំងសាសន៏ ហើយផ្សាយដំណឹងល្អទៅមនុស្ស" (កិច្ចកា ៨:១២ និង កិច្ចកា ២៨:៣១)។ កំនត់សំគាល់នៅក្នុង កិច្ចកា ៨:១២ យើងត្រូវបានប្រាប់ឱ្យដឹងថា នៅពេល មនុស្សសាសន៏សាមារី " ជឿតាមភីលីព ដែលគាត់ប្រាប់ដំណឹងល្អពីនគរនៃព្រះ ហើយពីព្រះនាមព្រះយេស៊ូវគ្រីស្ទវិញ នោះគេក៏ទទួលបុណ្យជ្រមុជទឹកទាំងប្រុសទាំងស្រី។"

បុណ្យជ្រមុជទឹក ជាពិធីសំរាប់អ្នកដែលត្រលប់បែរចេញពីអំពើបាប ហើយយល់និងជឿសេចក្តីពិត នៃដំណឹងល្អ ។ បុណ្យជ្រមុជទឹកពិតប្រាកដ កើតចេញពីជំនឿលើសេចក្តីពិត ។ ព្រះយេស៊ូវមានបន្ទូលថា " អ្នករាល់គ្នានឹងស្គាល់ចេក្តីពិត ហើយសេចក្តីពិតនោះនឹងប្រោសឱ្យអ្នករាល់គ្នាបានរួច " យ៉ូហាន ៨:៣២ ។ លោកប៉ូល ប្រាប់យើងនៅក្នុងគម្ពី អេភេសូ ៤:៤-៦ " មានរូបកាយតែ១ ហើយវិញ្ញាណតែ១ដូចជាទ្រង់ហៅអ្នករាល់គ្នាមក ក្នុងសេចក្តីសង្ឃមតែ១របស់ការងារអ្នករាល់គ្នាដែរ មានព្រះអម្ចាស់តែ១ សេចក្តីជំនឿតែ១ បុណ្យជ្រមុជតែ១ មានព្រះតែ១ គឺជាព្រះវបិតានៃទាំងអស់ ដែលទ្រង់ខ្ពស់លើទាំងអស់ គង់នៅកណ្តាលទាំងអស់ ហើយសណ្ឋិតនៅក្នុងទាំងអស់ " ។ " យើងត្រូវដឹងថា មានព្រះ១ និង ព្រះអម្ចាស់១ " (យ៉ូហាន ១៧:៣) យើងត្រូវជឿលើ "ជំនឿតែ១" និង " សេចក្តីសង្ឃឹមតែ១" ប្រសិនបើយើងរួមចំនែកក្នុង "បុណ្យជ្រមុជតែ១ " ។

យើងនឹងត្រលប់មកប្រធានបទបុណ្យជ្រមុជនេះម្តងទៀត ។

តើអ្វីជានគរនៃព្រះ?

ដូចដែលយើងអានព្រះគម្ពី យើងដឹងថា នគរនៃព្រះត្រូវបានបង្រៀន តាមរយៈព្រះយេស៊ូវគ្រីស្ទ និងសាវករបស់ទ្រង់ ។ យើងក៏អានផងដែរពីនគរព្រះនៅក្នុងគម្ពីសញ្ញាចាស់ ។ ឧទាហរណ៏ នៅក្នុងគម្ពីដានីយ៉ែល យើងត្រូវបានប្រាប់ថា នោះជានគរដែលព្រះនឹងតាំនៅលើផែនដី (ដានីយ៉ែល ២:៤៤) ។ អំណាចរបស់មនុស្សនឹងត្រូវបញ្ចប់ ។ នគររបស់ព្រះនឹងតាំងនៅពាលពេញពិភពលោក និងឋិតថេរនៅអស់កល្បជានិច្ច ។ ក្នុងគម្ពី ដានីយ៉ែល ៧:១៨ យើងឃើញថា " ពួកបរិសុទ្ធរបស់ព្រះដ៏ខ្ពស់បំផុត គេនឹងទទួលរាជ្យ ហើយនឹងបានរាជ្យនោះជារបស់ផងខ្លួនផងនៅជានិច្ច គឺអស់កល្បតទៅ " ។ អ្នកដែលទទួលបុណ្យជ្រមុជក្នុងព្រះនាមព្រះគ្រីស្ទ (កាឡាទី ៣:២៧) គឺជាអ្នកដែលត្រូវបានហៅថាពួកបរិសុទ្ធ" រ៉ូម ១:៧ ។ ដូចដែលបានលើកឡើងខាងលើ ប្រសិនបើ ពួកគេស្មោះត្រង់ ពួកគេនឹងនឹងទទួលរង្វាន់ជីវិតអស់កល្បជានិច្ចនៅពេលព្រះគ្រីស្ទយាងមក ហើយពួកគេនឹងទទួលបាន កិត្តិយស អំណាច និងអំណរនៅអស់កល្បជានិច្ចក្នុងនគរនៃព្រះ ។ នោះជាផ្នែកមួយនៃ**ផែនការរបស់ ព្រះជាមួយមនុស្ស** ។

ឥឡូវ គនរមួយនឹងត្រូវបង្កើតឡើងដោយផ្នែកជាច្រើន ។ នគរត្រូវតែមានស្តេចមួយ អ្នកគ្រប់គ្រងរួម រាជធានី អ្នកនៅក្រោមអំណាច និងទឹកដី ។ ព្រះគម្ពីប្រាប់យើងថា

ព្រះយេស៊ូវទ្រង់បានយាងមកជាស្តេច......

......នៅទូទាំងនគរដែលនឹងមកនោះ។ នៅពេលទ្រង់ឈរនៅពីមុខពីឡាត់ ជាអ្នកទោស អ្នកគ្រប់គ្រងជនជាតិ រ៉ូម៉ាំងបានសួរទ្រង់ថា " អ្នកជាស្តេចមែនឬ! " ។ ព្រះយេស៊ូវ បានឆ្លើយថា " លោកមានប្រសាសន៍ថាខ្ញុំជា ស្តេច នោះត្រូវហើយ ខ្ញុំបានកើតមក ហើយក៏ចូលក្នុងលោកីយនេះសំរាប់ការនោះឯង " យ៉ូហាន ១៨:៣៧។ ព្រះយេស៊ូវគ្រីស្ទបានប្រសូត្រមកដើម្បីធ្វើជាស្តេច ជាផ្នែកមួយសំខាន់នៃសេចក្តីពិតអំពីព្រះយេស៊ូវ។ ទេវតាកាព្រីយ៉ែល និយាយទៅកាន់ ម៉ារី ជាម្តាយអង្គព្រះយេស៊ូវ មុនពេលដែលទ្រង់ប្រសូត្រមក " បុត្រនោះនឹងបានជាធំឧត្តម ហើយគេនឹងហៅទ្រង់ ជាព្រះរាជបុត្រានៃព្រះដ៏ខ្ពស់បំផុត ព្រះអម្ចាស់ដ៏ជាព្រះទ្រង់នឹងប្រទានរាជ្យនៃហ្លួងដាវីឌ ជាព្ធយុកោទ្រង់ថ្វាយទ្រង់សោយ ទ្រង់នឹងសោយរាជ្យលើពួកវង្សរបស់យ៉ាកុប នៅអស់កល្បរៀងទៅ ហើយរាជ្យទ្រង់មិនផុតឡើយ។" លូកា ១:៣២-៣៣។ នៅក្នុងពាក្យរបស់ទេវតាបានបង្ហាញការពិតសំខាន់៧ដល់យើង :

ព្រះយេស៊ូវជាបុត្រានៃព្រះផង និងបុត្រានៃ ដាវីដផង។ (ទ្រង់បានប្រសូត្រមកក្នុងខ្សែស្រលាយពីពូជដាវីដ ម៉ារីម្តាយរបស់ទ្រង់ជាពូជស្តេចដាវីដ) ។ ទ្រង់ក៏នឹងសោយរាជ្យលើបល្ល័ង្ករបស់ស្តេចដាវីដ នៅអាណាចក្រអ៊ីស្រាអែលដ៏រាបរៀងទៅ។

ការទាំងនេះបាននាំយើងត្រលប់ទៅកាន់......

ការសន្យារបស់ព្រះជាមួយស្តេចដាវីដ.....

.......បានធ្វើឡើងនៅពេលដាវីដកំពុងសោយរាជ្យជាស្តេចនៃប្រទេសអ៊ីស្រាអែល នៅទីក្រុងយេរ៉ូសាឡិម ប្រហែលជា ៣០០០ ឆ្នាំកន្លងមកហើយ (សាំយូអែលទី២ ៧:១២-១៦) ។ ចំនុចនោះ យើងបានរៀនថា ព្រះបានសន្យាស្តេចដេវីដថា ទ្រង់នឹងប្រទានព្រះរាជបុត្រាមួយហើយស្តេចដាវីដ ដែលនឹងសោយរាជ្យលើបល្ល័ង្កទ្រង់ជារៀងរហូត ។ បន្ទូលរបស់ទេវតាទៅកាន់ម៉ារី មួយពាន់ឆ្នាំក្រោយមក បានបង្ហាញយ៉ាងច្បាស់ថា នរណាជាបុត្រាសន្យានោះ ។ ឥឡូវព្រះយេស៊ូវមិនដែលបានសោយរាជជាស្តេចនៃអ៊ីស្រាអែល លើបល្ល័ង្កស្តេចដាវីដទេ ។ ទ្រង់ត្រូវបានគេបដិសេដ្ឋ ដោយសាសន៍អ៊ីស្រាអែលនោះ ហើយ " ត្រូវបានដឹកដូចជាចៀមទៅសំលាប់ " អេសាយ ៥៣:៧ ។ នៅពីលើឈើឆ្កាងរបស់ទ្រង់ មានការសរសេរពីសំណាក់ពួកអ្នកដឹកនាំ សើចចំអកបន្ទូលរបស់ទ្រង់ " យេស៊ូវពីស្រុកណាសារែត ស្តេចនៃសាសន៏យូដា" អំណះអំណាងនោះ នឹងត្រូវបានបង្ហាញជាការពិត ។

ការសន្យារបស់ព្រះជាមួយដាវីដ នឹងត្រូវបានសំរេច តែត្រូវមានរឿងមួយចំនួនត្រូវកើតឡើងមុនសិន :

- ព្រះយេស៊ូវផ្ទាល់ ត្រូវតែយាងត្រលប់មកផែនដីវិញ
- ដាវីដផ្ទាល់ ត្រូវតែរស់ពីសុគតឡើងវិញ
- អ៊ីស្រាអែលជាប្រទេស ត្រូវតែទទួលទ្រង់ដោយបន្ទាបខ្លួន ខណៈដែលកាលពីមុនបានបដិសេដ្ឋទ្រង់ជាស្តេច
- អាណាចក្រអ៊ីស្រែអែល នៅក្រោមអង្គព្រះគ្រីស្ទ នឹងត្រូវតែស្តារឡើងវិញ នៅក្នុងទឹកដីដែលដាវីដបានសោយរាជ្យ ។

រឿងរាវដែលកំពុងកើតឡើងនៅក្នុងពិភពលោក បង្ហាញយើងឱ្យដឹងថា ព្រឹត្តិការណ៏ដ៏អស្ចារ្យទាំងនេះជិតមកដល់ហើយ ។

អ៊ីស្រាអែល ប្រជាជនពិសេស

ឥឡូវយើងត្រូវតែសួរថា : តើអ្វីក្លាយជានគរ និងបល្ល័ង្ករបស់ដាវីដ? វាឥតមានទេពេលបច្ចុប្បន្ននេះ ។ នគរបានមកដល់ទីបញ្ចប់ ដោយសារ អ៊ីស្រាអែល ប្រទេសដែលព្រះបានជ្រើសរើសឱ្យក្លាយជា " រាស្ត្របរិសុទ្ធចំពោះព្រះអម្ចាស់ជាព្រះរបស់អ្នក " ចោទិយកថា ៧:៦ មិនបានគោរពព្រះរបស់ពួកគេ ។ ព្រះមិនបានដាក់ទីបញ្ចប់ឱ្យគេជារៀងរហូតនោះទេ ។ នេះជាអ្វីដែលលោកប៉ូលនិយាយនៅក្នុង រ៉ូម ១១:១-២ " តើព្រះបានបដិសេធរាស្ត្ររបស់ទ្រង់ឬ? តាមការពិត ! ...ព្រះមិនបានបដិសេធចោលរាស្ត្ររបស់ទ្រង់ អ្នកដែលទ្រង់បានស្គាល់ជាមុន " ។

ទ្រង់មានបន្ទូលម្តងទៀត (ខ ២៥-២៧) " សាសន៍អ៊ីស្រាអែលកើតមានសេចក្តីរឹងរបឹងប៉ុន្មានភាគនេះទៅហើយ ទាល់តែសាសន៍ដ៏ទៃទាំងប៉ុន្មានបានចូលជឿគ្រប់ចំនួន ។ " ដូច្នេះហើយ អ៊ីស្រាអែលទាំងអស់ (មានន័យថា អ៊ីស្រាអែលទាំងផ្នែកព្រលឹងវិញ្ញាណ និងសាច់ឈាម) នឹងត្រូវបានសង្គ្រោះ ដូចដែលបានចែងទុកមក : " ព្រះដ៏ប្រោសឱ្យរួច ទ្រង់នឹងចេញពីស៊ីយ៉ូន ទ្រង់នឹងបង្វែរសេចក្តីទមិលល្មើសចេញពីយ៉ាកុបទៅ នោះហើយជាសេចក្តីសញ្ញាដែលអញតាំងនឹងគេ ក្នុងកាលដែលអញបានដោះបាបគេចេញហើយ ។ "

ព្រះបានចាត់ហោរាអេសេគាល ឱ្យទៅនិយាយនឹងស្តេចចុងក្រោយរបស់អ៊ីស្រាអែល ដែលបានគង់លើបល្ល័ង្កដាវីដ ស្តេចសេដេគា " អញនឹងធ្វើឱ្យត្រឡប់ត្រឡិន ត្រឡប់ត្រឡិនទៅ នោះក៏មិននៅទៀតដែរ ដរាបដល់អ្នកនោះកើតឡើង ដែលមានច្បាប់ទទួល រួចអញនឹងប្រគល់ដល់អ្នកនោះ ។ " អេសេគាល ២១:២៧ ។ ដូច្នេះវាបានកើតឡើង ។ បាប៊ីឡូន ក្រិច និង ចក្រភពរ៉ូម បានឈ្លានពានអ៊ីស្រាអែល នៅពេលខុសៗគ្នាក្នុងប្រវត្តិសាស្ត្រ ។ នៅពេលព្រះយេស៊ូវប្រសូត្រ ទឹកដីថិតនៅក្នុងកណ្តាប់ដៃរបស់ជនជាតិរ៉ូម៉ាំង ។

ព្រះយេស៊ូវខ្លួនទ្រង់បានទាយទុកមុនថា ទីក្រុងយេរូសាឡិមនឹងត្រូវដួលរលំ ហើយសាសន៍យូដានឹងត្រូវរប៉ាត់រប៉ាយ ។ ទ្រង់មានបន្ទូលថា " គេ (សាសន៍យូដា) នឹងត្រូវដួលនៅក្រោមមុខដាវ ហើយនឹងត្រូវដឹកនាំទៅជាឈ្លើយ ដល់អស់ទាំងនគរ ក្រុងយេរូសាឡិម នឹងត្រូវសាសន៍ដ៏ទៃជាន់ឈ្លី ដរាបដល់គ្រារបស់សាសន៍ដ៏ដៃបានសំរេច " លូកា ២១:២៤ ។ ដូច្នេះហើយ នៅឆ្នាំ ៧០ក្រោយ គ.ស ទីក្រុងយេរូសាឡិមបានដួលរលំ ហើយចាប់ពីពេលនោះរហូតមកដល់សម័យបច្ចុប្បន្ន សាសន៍យូដាត្រាចចរនៅគ្រប់ជាតិសាសន៍ ។

សាសន៍យូដា ស្មរបន្ទាល់របស់ព្រះ

ប៉ុន្តែ នោះជាផ្នែកមួយនៃផែនការដ៏អស្ចារ្យរបស់ព្រះ ដែលសាសន៍យូដាត្រូវតែត្រលប់មកកាន់ទឹកដីកំនើតរបស់គេ បន្ទាប់ពី ២០០០ ឆ្នាំ។ ជាឧទាហរណ៏ តាមរយៈហោរា អេសេគាល ព្រះមានបន្ទូលនៅក្នុងជំពូក ៣៧:២១-២២ " អញនឹងយកកូនចៅអីស្រាអែល ចេញពីអស់ទាំងសាសន៏ដែលគេបានទៅនោះ ហើយប្រមូលមកពីគ្រប់ទិស នាំចូលទៅក្នុងស្រុករបស់ផងខ្លួន អញនឹងធ្វើឱ្យគេរួមគ្នាជានគរតែ១នៅក្នុងស្រុកនោះ គឺនៅលើអស់ទាំងភ្នំនៃស្រុកអីស្រាអែល នោះនឹងមានស្តេចតែ១អង្គ ធ្វើជាស្តេចនៅលើគេគ្រប់គ្នា"។

នៅក្នុងប្រវត្តិសាស្ត្រយូលង់ និងជូចត់របស់ពួកគេ រឿងរ៉ាវដែលបានកើតឡើងចំពោះសាសន៏យូដាបានបង្ហាញសេចក្តីពិតពីព្រះបន្ទូលរបស់ព្រះ។ ព្រះមានបន្ទូលពីពួកគេថា " ឯងរាល់គ្នាជាស្មរបន្ទាល់របស់អញ...ហើយគឺអញនេះគឺជាព្រះ " អេសាយ ៤៣:១២។

ទីសំគាល់នៃសម័យយើង

នៅក្នុងប្រវត្តិសាស្ត្រថ្មីៗនេះ និងពេលបច្ចុប្បន្ន យើងឃើញសាសន៏យូដាត្រលប់មក" ទឹកដីរបស់ពួកគេ"។ ប៉ុន្តែ មិនទាន់មាន "ស្តេច១អង្គ" នៅឡើយ។ យើងកាន់តែនៅជិតការយាងត្រលប់មករបស់ទ្រង់ហើយ !

ព្រះយេស៊ូវបានផ្តល់ឱ្យយើងនូវទីសំគាល់ផ្សេងៗទៀត ដែលយើងស្វែងរកមុនពេលទ្រង់យាងត្រលប់មក។ ទ្រង់មានបន្ទូលថា នឹងមាន " នៅលើផែនដី នឹងមានសេចក្តីលំបាកនៅគ្រប់ទាំងសាសន៏....មនុស្សនឹងស្រយុតចិត្តដោយភ័យ ហើយដោយទន្ទឹងចាំការដែលត្រូវមកលើផែនដី " លូកា ២១:២៥-២៦។ តើនោះមិនមែនជាអ្វីដែលយើងឃើញពេលបច្ចុប្បន្ននេះទេ? ព្រះយេស៊ូវបានបន្ថែមនៅ ខ ៣១ : " កាលណាអ្នករាល់គ្នាឃើញការទាំងនោះកើតមក នោះត្រូវដឹងថា នគរព្រះជិតដល់ហើយ"។ ហើយមានទីសំគាល់ជាច្រើនផ្សេងទៀត ដែលយើងមិនអាចមើលឃើញពេលឥឡូវនេះ។ តែគ្រប់ចំនុចទាំងអស់មានរបៀបដូចគ្នា។

ឥឡូវ យើងនឹងត្រលប់ទៅមើលសេចក្តីសន្យា។ ប្រសិនបើព្រះយេស៊ូវត្រូវសោយរាជ្យលើបល្ល័ង្ក ដាវីដ ជាបិតា នោះទីក្រុងយេរូសាឡិម គឺជាកន្លែងដែលទ្រង់នឹងត្រូវសោយរាជ្យលើផែដីទាំងមូល ព្រោះទីនោះជាកន្លែងដែលដាវីដបានសោយរាជ្យដែរ។ យេរេមា ៣:១៧ "នៅគ្រានោះ គេនឹងហៅ...

ក្រុងយេរូសាឡិមជាដាបល្ល័ង្កនៃព្រះយេហូវ៉ា

ព្រះយេស៊ូវអង្គទ្រង់មានបន្ទូលថាទីក្រុងយេរូសាឡិមជា "ទីក្រុងនៃស្តេចដ៏ធំ " ម៉ាថាយ ៥:៣៥។ ព្រះមានបន្ទូលថាទ្រង់នឹងតាំងស្តេចរបស់ទ្រង់ឡើងនៅ "ស៊ីយ៉ូន ជាភ្នំបរិសុទ្ធរបស់ទ្រង់ " ទំនុកដំកើង ២:៦ "អោយអ្នកដែលទ្រង់បានជ្រើសតាំង" - ព្រះយេស៊ូវ ឬ ព្រះមេស៊ី — ព្រះមានបន្ទូលថា " នោះអញនឹងឱ្យសាសន៍ទាំងឡាយដល់ឯង ទុកជាមរដក ហើយអស់ទាំងចុងផែនដីទុកជាកេរ្តិ៍អាកររបស់ឯង " ទំនុកដំកើង ២:៨។ នេះបង្ហាញយើងឱ្យដឹងថា ទីក្រុងយេរូសាឡិម នឹងក្លាយជាចំនុចកណ្តាលនៃនគរព្រះនៅទូទាំងផែនដី។ ស្តេចដែលនឹងសោយរាជ្យនៅស៊ីយ៉ូន នឹងបានជាខ្ពស់បំផុតនៅលើផែនដី (សាការី ១៤:៩)។ យើងអានក្នុង ទំនុកដំកើង ៧២:១១ " ពួកក្សត្រទាំងអស់ នឹងផ្តួលខ្លួនក្រាបចុះនៅចំពោះទ្រង់ ហើយអស់ទាំងនគរនឹងចំណុះទ្រង់ដែរ "។

ឥឡូវយើងបានឃើញមកហើយថា......

ពួកបរិសុទ្ធដែលស្មោះត្រង់របស់ព្រះគ្រីស្ទនឹងគ្រប់គ្រងជាមួយទ្រង់....

នៅក្នុងនគរព្រះ។ ព្រះយេស៊ូវអង្គទ្រង់បានប្រាប់ពេត្រុសថា អស់អ្នកដែលដើរតាមទ្រង់នឹងរួមចំណែកក្នុងសិរីល្អរបស់ទ្រង់នៅថ្ងៃដែលនឹងមកដល់នោះ (ម៉ាថាយ ១៩:២៨)។ សាវកប៉ូល និយាយថា " បើយើងទ្រាំទ្រនោះ យើងនឹងសោយរាជ្យជាមួយទ្រង់ " ធីម៉ូថេទី២ ២:១២ ហើយនៅក្នុងបន្ទូលចុងក្រោយទៅដល់ពួកបរិសុទ្ធរបស់ទ្រង់ដែលកំពុងរង់ចាំ ព្រះយេស៊ូវផ្តល់ការសន្យាធំមួយ " ឯអ្នកណាដែលឈ្នះ នោះអញនឹងឱ្យអង្គុយលើបល្ល័ង្កជាមួយនឹងអញ " វិវរណៈ ៣:២១។

ពួកអ្នកបរិសុទ្ធច្រៀងថ្វាយស្តេចពួកគេ " សត្វសិង្ហដែលកើតពីពូជអំបូរយូដា គឺជាឫសកែវនៃហ្លួងដាវីឌ ".....
" ក៏តាំងពួកគេឡើងជានគរ ហើយជាពួកសង្ឃ ថ្វាយដល់ព្រះនៃយើងរាល់គ្នា ឱ្យពួកគេបានសោយរាជ្យលើផែនដី " វិវរណៈ ៥:៩ និង ១០។

ផែនដីជាមរដកដែលសន្យាសំរាប់អ្នកសុចរិត

នេះជាការសន្យាសាមញ្ញមួយពីអ្វីដែលយើងបាននិយាយពីមុនអំពីនគរព្រះ ។ តែព្រះយេស៊ូវបានពោលបញ្ជាក់យ៉ាងច្បាស់ដោយអង្គទ្រង់ " មានពរហើយ អស់អ្នកដែលស្លូតត្រង់ ដ្បិតអ្នកទាំងនោះនឹងគ្រងផែនដីជាមរដក " ម៉ាថាយ ៥:៥ ។ ដាវីឌបាននិយាយដូចគ្នា នៅទំនុកដំកើង ៣៧:១១ " ឯមនុស្សរាបសាគេនឹងបានផែនដីជាមរដក ហើយនឹងបានចិត្តរីករាយ ដោយសេចក្តីក្សេមក្សាន្តដ៏បរិបូរ " ។

ព្រះគ្រីស្ទ និងពួកអ្នកបរិសុទ្ធរបស់ទ្រង់ នឹងគ្រងរាជ្យលើអីស្រាអែលដែលកើតជាថ្មី (ភាពគ្មានជំនឿរបស់គេនឹងត្រូវយកចេញ) និងលើសាសន៍ដទៃ អ្នកដែលរត់គេចពីសេចក្តីជំនំជំរះរបស់ព្រះ ។ នេះនឹងក្លាយជា.....

អ្វីៗដែលមិនចេះពុកផុយនៃនគរព្រះ....

អ្នកដែលនឹងរីករាយនឹងគុណប្រយោជន៍ដ៏អស្ចារ្យ ដែលនឹងទទួលបាននៅពេលអង្គព្រះយេស៊ូវគ្រីស្ទជាស្តេច ។ នៅពេលនោះ អីស្រាអែលនឹងក្លាយជាប្រទេសសំខាន់បំផុតមួយ (អេសាយ ៦០:១០-១៥) ។ ហោរារបស់ព្រះបានប្រកាស់ថា " ដ្បិតសាសន៍ណា នឹងនគរណាដែលមិនព្រមគោរពដល់ឯងនោះនឹងត្រូវវិនាស អើ សាសន៍ទាំងនោះនឹងត្រូវសាបសូន្យបាត់ទៅអស់រលីង " អេសាយ ៦០:១២ ។

អស់អ្នកដែលគ្រងរាជ្យជាមួយព្រះគ្រីស្ទ នឹងមិនចេះស្លាប់ឡើយ តែទោះបីក្នុងចំនោមមនុស្សដែលអាចស្លាប់នៅលើផែនដី រយះពេលនៃការរស់នៅនឹងកើនឡើងយ៉ាងខ្លាំង ។ យើងត្រូវបានប្រាប់ថាអ្នកដែលស្លាប់នៅអាយុ ១០០ឆ្នាំ នោះគេនឹងរាប់ថា ជាក្មេងទេ.....អេសាយ ៦៥:២០ ។ វាមិនមែនជាការពិបាកសំរាប់យើង ក្នុងការមើលឃើញថាតើជីវិតរបស់យើងប្រសើរក៏វិតប៉ុណ្ណានោះទេនៅពេលមនុស្សជាតិទាំងអស់ត្រូវបានគ្រប់គ្រងដោយ

ក្រិត្យវិន័យមួយដែលសុក្រឹត យុត្តិធម៌ និងពោរពេញដោយគតិបណ្ឌិត

ដែលនឹងនាំមកនូវអំណរ និងសន្តិភាព មកឱ្យមនុស្សទាំងអស់ និងសិរីល្អដល់ព្រះ ។ ការអាក្រក់ និងភាពវេទនា ទាំងប៉ុន្មានដែលនៅលើពិភពលោកយើងនេះកើតមកពីអ្នកគ្រប់គ្រង និងច្បាប់មិនល្អទាំងឡាយ ! ប៉ុន្តែ បន្ទាប់មក នោះនឹងមានភាពខុសគ្នាយ៉ាងខ្លាំង ! ព្រះគម្ពីរប្រាប់យើង ទ្រង់នឹងបង្រៀនយើងពីផ្លូវរបស់ទ្រង់ ដើម្បីឱ្យយើងដើរតាមផ្លូវទ្រង់ ។ " ក្រិត្យវិន័យនឹងចេញពីក្រុងស៊ីយ៉ូនទៅ ហើយព្រះបន្ទូលនៃព្រះយេហូវ៉ា ពីក្រុងយេរូសាឡិម " អេសាយ ២:៣ ។ ក្រិត្យវិន័យនោះល្អក្រៃលែង ហើយមានឥទ្ធិពល ដែលមនុស្សប្រាថ្នា ចង់ដឹង ហើយគេក៏រក្សាក្រិត្យវិន័យនោះ ។ គេនឹងពោលថា (មើលខដដែល) " ចូរយើងឡើងទៅឯភ្នំ នៃព្រះយេហូវ៉ា ដល់ព្រះវិហារនៃព្រះរបស់ពួកយ៉ាកុបចុះ ទ្រង់នឹងបង្រៀនយើងពីផ្លូវរបស់ទ្រង់ នោះយើងនឹង ដើរតាមផ្លូវទាំងនោះ " ។

ព្រះពរនៃសម័យកាលដែលនឹងមកដល់

ហោរាប្រាប់យើងនៅក្នុងខ៤ ថាសង្គ្រាមនឹងត្រូវបញ្ចប់ ហើយគ្រឿងសព្វាវុធសង្គ្រាម នឹងត្រូវប្រែក្លាយជា ឧបករណ៍សំរាប់ការធ្វើកសិកម្មដែលពោពេញដោយសន្តិភាពពីដី ។ គ្រប់ជាតិសាសន៍ទាំងអស់ នឹងលែងមាន អាវុធ ។ មីកា ៤:៣ " អស់ទាំងនគរនឹងលែងលើកដាវច្បាំងគ្នាទៀត ក៏មិនរៀនវិជ្ជាចំបាំងទៀតតទៅ " ។

ការយាងមករបស់ព្រះគ្រីស្ទ គឺជាដំណោះស្រាយតែមួយគត់សំរាប់ពិភពលោកដែលជោកជាំ និងនឿយហត់ដោយសង្គ្រាម ។ ទ្រង់គឺជា **" ព្រះអង្គម្ចាស់នៃសន្តិភាព "** ។ " ឯសេចក្តីចំរើននៃរដ្ឋបាលទ្រង់ នឹងសេចក្តីសុខសាន្តរបស់ទ្រង់ នោះនឹងមិនចេះផុតពីបល្ល័ង្ករបស់ដាវីឌ នឹងនគរទ្រង់ឡើយ ដើម្បីនឹងតាំងឡើង ហើយទប់ទល់ ដោយសេចក្តីយុត្តិធម៌ នឹងសេចក្តីសុចរិត ចាប់តាំងពីឥឡូវនេះ ជារៀងដរាបទៅ គឺសេចក្តីឧស្សាហ៍របស់ព្រះយេហូវ៉ានៃពួកពលបរិវារ នឹងសំរេចការនេះ " អេសាយ ៩:៧ ។ សំរាប់ពេលដែល មានព្រះពរនេះ ព្រះយេស៊ូវបានបង្រៀនសិស្សរបស់ទ្រង់ឱ្យអធិស្ឋាន សូមឱ្យរាជ្យទ្រង់បានមកដល់ សូមឱ្យបំណងព្រះហឫទ័យទ្រង់បានសំរេចលើផែនដីដូចនៅឋានសួគ៌ដែរ ។ ម៉ាថាយ ៦:១០ ។ នៅពេលព្រះយេស៊ូវបានប្រសូត្រនៅបេថ្លេហិម ទេវតាបានច្រៀងបទភ្លេងគួរជាទីពេញចិត្ត " សួស្តីដល់ព្រះ នៅស្ថានដ៏ខ្ពស់បំផុត ហើយសេចក្តីសុខសាន្តនៅផែនដី នៅកណ្តាលមនុស្ស ដែលជាទីគាប់ព្រះហឫទ័យ ដល់ទ្រង់ " លូកា ២:១៤ ។ តែលុះត្រាតែ ព្រះយេស៊ូវគ្រងរាជ្យជាស្តេច ទើបព្រះបន្ទូលនោះបានសំរេច ។

"សិរីល្អដល់ព្រះ"ជាកាព្វកិច្ចដំបូងរបស់មនុស្ស ។ សេចក្តីសុខសាន្ត នឹងមកតាមក្រោយ ។ ខណៈដែលវាជាក្រឹត្យវិន័យរបស់ព្រះ នូវរាល់ទំនាក់ទំនងរបស់ទ្រង់ជាមួយមនុស្ស ដែលព្រះមានបន្ទូលថា "គ្មានសេចក្តីសុខទេ " "សំរាប់មនុស្សអាក្រក់ " អេសាយ ៥៧:២១ ។

ដើម្បីមើលឃើញរូបភាពពេញលេញនៃសេចក្តីអំណរ និងព្រះពរនៃការគ្រង់រាជ្យរបស់ព្រះគ្រីស្ទ សូមអានទំនុកដំកើង ៧២ ។ នៅពីមុខគំនិតរបស់យើង មានរូបភាពដ៏ល្អមួយ គឺស្តេចកំពុងគ្រងរាជ្យដោយសេចក្តីសុចរិត ព្រះចេស្តារបស់ទ្រង់លាតត្រដាងនៅពាសពេញពិភពលោក នៅខ ៧ "នៅក្នុងគ្រាព្រះរាជបុត្រានោះមនុស្សសុចរិត នឹងមានសេចក្តីចំរើនឡើង ហើយនឹងមានសេចក្តីសុខជាបរិបូរ ដរាបដល់ព្រះចន្ទរលត់សូន្យទៅ " ។ គ្មានអំពើហិង្សា ឬអំពើព្រៃផ្សៃ គ្មានការជិះជាន់ ការចង់បាន ឬភាពវេទនា ភាពក្រីក្រ ហើយជនដែលចិតក្នុងសេចក្តីត្រូវការនឹងត្រូវបានទទួលការថែរក្សា ដែលមិនធ្លាប់មានពីមុនមក ។

"សូមឱ្យព្រះនាមទ្រង់នឹងស្ថិតស្ថេរនៅជាដរាប គឺនឹងមាននៅអស់អំឡុងដែលនៅមានព្រះអាទិត្យភ្លឺតទៅ ហើយមនុស្សទាំងឡាយ នឹងហៅទ្រង់ថាអ្នកមានពរ.....

គ្រប់ជាតិសាសន៍ទាំងអស់នឹងទទួលបានព្រះពរដោយសារទ្រង់.....

....គ្រប់ជាតិសាសន៏ទាំងអស់នឹងហៅទ្រង់ថាអ្នកដែលមានពរ " ។ ដាវីឌបានបញ្ចប់ដោយពាក្យសរសើរដំកើងចំពោះអ្នកនិពន្ធដ៏អស្ចារ្យនៃផែនការដែលពោរពេញដោយសិរីរុងរឿងនេះ
"សូមឱ្យព្រះនាមដ៏រុងរឿងរបស់ទ្រង់ បានប្រកបដោយព្រះពរ នៅអស់កល្បជានិច្ច ហើយ......

សូមឱ្យផែនដីទាំងស្រុងបានពេញដោយសិរីល្អនៃទ្រង់ "

អាម៉ែន អាម៉ែន ។" ហើយនោះហើយគឺអ្វីដែលយើងបាននិយាយតាំងពីដំបូង ជា **ផែនការរបស់ ព្រះជាមួយមនុស្ស ។**

ទោះបីជា ផែនដីត្រូវដោះឱ្យរួចពីបណ្តាសាដែលមាន (លោកុប្បត្តិ ៣:១៧-១៨)។ យើងបាននិយាយពីមុនថា នោះជាការងាររបស់ព្រះគ្រីស្ទ ក្នុងការយកឥទ្ធិពលនៃអំពើបាបរបស់អាដាមចេញ។ នៅពេលទ្រង់គ្រងរាជ្យ នោះទ្រង់នឹងនាំឱ្យមានផលជាបរិបូរណ៍ (ទំនុកដំកើង ៦៧:៦ ទំនុកដំកើង ៧២:១៦) "អ្នកភ្ជួររាស់នឹងធ្វើការ ដរាបដល់ជួបនឹងអ្នកដែលសាបព្រោះ" អេម៉ូស ៩:១១-១៥។ នោះមានន័យថា ការច្រូតកាត់ចំការ នឹងអស្ចារ្យក្រៃលែង ដែលទិន្នផល កម្រនឹងប្រមូលមុនពេលដែលរដូវច្រូតកាត់មកដល់ម្តងទៀត។

ព្រះគ្រីស្ទនឹង "ធ្វើឱ្យទាំងអស់ឡើងជាថ្មី" (វិវរណៈ ២១:៥)។ ទ្រង់ជាអ្នកប្រោសឱ្យជាដ៏អស្ចារ្យនៃពូជសាសន៍របស់យើង ទាំងផ្នែករាង្គកាយ និងព្រលឹងវិញ្ញាណ។ជំងឺ និងរោគាទាំងឡាយ នឹងបាត់បង់ (អេសាយ ៣៣:២៤) ហើយនឹងលែងមានសេចក្តីស្លាប់ទៀតហើយ។

លោកប៉ូលប្រាប់យើងនៅក្នុង កូរិនថូសទី១ ១៥:២៥-២៦ ថាព្រះគ្រីស្ទ "ដ្បិតគួរឱ្យទ្រង់បានសោយរាជ្យទាល់តែដាក់អស់ទាំងខ្មាំងសត្រូវនៅក្រោមព្រះបាទទ្រង់ ឯខ្មាំសត្រូវក្រោយបង្អស់ ដែលត្រូវបំផ្លាញ គឺជាសេចក្តីស្លាប់ "។

មួយពាន់ឆ្នាំដំបូងនៃនគរព្រះ ត្រូវបាននិយាយថាជា
សហសវត្ស....

នឹងជាអ្វីចុងក្រោយបង្អស់ដែលព្រះយេស៊ូវ ជាស្តេច ធ្វើក្នុងការប្រមូលផ្តុំអ្វីៗទាំងអស់ឱ្យស្របនឹងព្រះឬទ័យរបស់ព្រះ។ នៅចុងក្រោយពីពេលនោះ នឹងមានការផ្លាស់ប្រែ។ អស់អ្នកដែលបានស្លាប់ នៅអំឡុងពេលមួយពាន់ឆ្នាំនោះ នឹងត្រូវរស់ពីស្លាប់ហើយទទួលការជំនុំជំរះ (វិវរណៈ ២០:១២-១៤)។ នោះក្នុងជំនុំជំរះពេលព្រះគ្រីស្ទត្រលប់មកនោះ មនុស្សអាក្រក់នឹងត្រូវវិនាស នោះអ្នកសុច្ចរិតនឹងត្រូវរស់នៅអស់កល្បជានិច្ច។

នៅគ្រានោះសេចក្តីស្លាប់នឹងត្រូវរលាយបាត់បង់ជារៀងរហូតពីផែនដី។ មានតែពូជដែលមិនចេះស្លាប់ដែលនៅជាមួយព្រះ ដែលជាអ្នកដែលនឹងបំពេញផែនដីទាំងមូលដោយសិរីល្អ និងការសរសើររបស់ទ្រង់។

ការងារសង្គ្រោះរបស់ព្រះគ្រីស្ទ នឹងបានចប់សព្វគ្រប់ ហើយ "គ្រប់របស់ទាំងអស់នៅក្រោមទ្រង់" (កូរិនថូសទី១ ១៥:២៨) ។

ព្រះនឹងធ្វើជាគ្រប់ទាំងអស់ក្នុងគ្រប់ទាំងអស់.....(កូរិនថូសទី១ ១៥:២៨)

ហើយនៅទីបំផុតនឹងត្រូវបើកសំដែងដល់មនុស្ស។ នៅក្នុងវិវរណៈ ២១:៣-៤ យើងនឹងទទួលបានតែមួយប្រព្រិចភ្នែកដែលជាសិរីល្អ នៃផែនការដ៏អស្ចារ្យរបស់ព្រះ " មើល រោងឧបោសថរបស់ព្រះ បាននៅជាមួយនឹងមនុស្សហើយ ទ្រង់នឹងគង់នៅជាមួយគេ គេនឹងធ្វើជារាស្ត្រទ្រង់ ព្រះទ្រង់នឹងជូតអស់ទាំងទឹកភ្នែកពីភ្នែកគេចេញ ហើយ.......

គ្មានសេចក្តីស្លាប់ទៀតទេ.....

គ្មានសេចក្តីសោកសង្រេង ឬសេចក្តីទួញយំ ឬទុក្ខលំបាក ណាទៀតឡើយ ដ្បិតសេចក្តីមុនទាំងប៉ុន្មាន បានកន្លងបាត់ទៅហើយ "។

នៅក្នុងជំពូកចុងក្រោយនៃព្រះគម្ពី យើងអានច្រើនអំពី "ការប្រោសឱ្យជា" នៃលោកីយដែលមានជំងឺ ហើយនៅទីនោះ (វិវរណៈ ២២:៣) យើងនឹងជួបតែដំណឹងដែលរំភើប និងមានអំណរ។

នឹងលែងមានសេចក្តីបណ្តាសាទៀតឡើយ "

ហើយនេះជាការបើកសំដែងផ្នែកចុងក្រោយនៃផែនការរបស់ព្រះជាមួយមនុស្ស។

ប្រសិនបើយើងក្រលេកមើលពីសភាពអាក្រក់នៃលោកីយដែលគ្មានព្រះ យើងប្រហែលជាមិនមើលឃើញទ្រង់ទ្រាយនៃផែនការនោះទេ។ ប៉ុន្តែ យើងត្រូវតែក្រលេកមើលដោយក្រសែភ្នែកនៃជំនឿចំពោះការងារដែលនៅចុងបញ្ចប់។ នៅពេលដែលអ្វីៗដែលគ្មានតំលៃ ជាសំនល់ និងជារបស់ដែលគេមិនត្រូវការ ត្រូវបានបំបាត់ចេញ ជាពេលដែលការងារបានចប់សព្វគ្រប់ នគរព្រះនឹងពោពេញដោយភាពស្រស់ស្អាត។

យើងមិនគួរអនុញ្ញាតិឱ្យសកម្មភាពរបស់មនុស្សរាំងបាំងយើងពីការមើលឃើញផែនការដ៏អស្ចារ្យរបស់ព្រះទេ។ ការងាររបស់មនុស្សនឹងកន្លងផុតទៅ គោលបំណងរបស់ព្រះនឹងមិនបរាជ័យឡើយ។

តើយើងនឹងចូលទៅក្នុងរាជវាំងដ៏ស្រស់ស្អាតនេះ ហើយរស់នៅជាមួយស្តេច ក្នុងសិរីល្អរបស់ទ្រង់ ដោយរបៀបណា?

ការសន្យារបស់ព្រះជាមួយអ័ប្រាហាំ

ដំបូងយើងនឹងក្រលេកមើលអាប់រ៉ាម ដែលត្រូវបានត្រាស់ហៅដោយព្រះពី អើរជាកន្លែងដែលគាត់រស់នៅ។ ព្រះបានប្រាប់គាត់ឱ្យទៅ កាណាន ជាទឹកដីដែលព្រះសន្យានឹងឱ្យគាត់ជារៀងរហូត។

លោកុប្បត្តិ ១២:១-៣ ព្រះជាម្ចាស់បានមានបន្ទូលទៅកាន់អាប់រ៉ាម "ចូរឯងចេញពីស្រុក ពីញាតិសន្តាន នឹងពីព្រះឪពុកឯង ទៅនៅឯស្រុកដែលអញនឹងបង្ហាញឯងចុះ អញនឹងបង្កើតនគរ១យ៉ាងធំពីឯង អញនឹងឱ្យពរដល់ឯង ទាំងលើកឈ្មោះឯងជាធំផង ឯងនឹងបានជាទីបញ្ចេញព្រះពរដល់មនុស្សទាំងឡាយ អញនឹងឱ្យពរដល់អ្នកណាដែលឱ្យពរដល់ឯង គ្រប់ទាំងគ្រួនៅផែនដីនឹងបានពរដោយសារឯង"។

លោកុប្បត្តិ ១៣:១៤-១៧ ព្រះយេហូវ៉ាមានបន្ទូលនឹងអាប់រ៉ាម បន្ទាប់ពីឡុតបានឃ្លាតចេញទៅ "ចូរឯងងើបភ្នែកឡើងឥឡូវ ហើយមើលពីកន្លែងឯងនោះ ពីខាងជើង ខាងត្បូង ខាងកើត ហើយខាងលិចចុះ ដ្បិតស្រុកទាំងប៉ុន្មានដែលឯងមើលឃើញ នោះអញនឹងឱ្យដល់ឯង នឹងពូជឯងជាដរាបទៅ អញនឹងធ្វើឱ្យពូជឯងបានចំរើនឡើងដូចជាធូលីដី បានជាបើអ្នកណាអាចនឹងរាប់ធូលីដីបាន នោះនឹងរាប់ពូជឯងបានដែរ ចូរឯងក្រោក ហើយដើរចុះឡើងចុះក្នុងស្រុកនេះ តាមបណ្តោយ និងទទឹងចុះ ដ្បិតអញនឹងឱ្យដល់ឯងហើយ"។

ផែនទី និងបញ្ជីការសន្យាមួយចំនួននៅខាងក្រោមបានយកមកពីខិតប័ណ្ណ "គន្លឹះដើម្បីយល់ព្រះគម្ពី"។

១. ការសន្យាលក្ខណៈជាតិ — ព្រះបានសន្យាថាអ័ប្រាហាំ នឹងក្លាយជាប្រទេសមួយដ៏អស្ចារ្យ ។

២. ការសន្យាផ្ទាល់ខ្លួន — ឈ្មោះរបស់អ័ប្រាហាំនឹងបានអស្ចារ្យនៅលើផែនដី ហើយគាត់នឹងជាទីបញ្ចេញព្រះពរ ។

៣. ការសន្យាគ្រួសារ — ព្រះនឹងឱ្យពរដល់អ្នកណាដែលឱ្យពរដល់អ័ប្រាហាំ ហើយដាក់បណ្តាសាដល់អ្នកណាដែលដាក់បណ្តាសាដល់គាត់ ។

៤. ការសន្យាជាអន្តរជាតិ — តាមរយៈទ្រង់គ្រប់គ្រួទាំងអស់នៅលើផែនដីនឹងទទួលបានព្រះពរ ។



បន្ទាប់ពីអាប់រ៉ាមបានរើមកកាន់ទឹកដីសន្យា (កាណាន) ព្រះមានបន្ទូលមកគាត់ថា "ឈ្មោះឯងមិនត្រូវហៅថា អាប់រ៉ាមទៀតទេ គឺត្រូវហៅថា អ័ប្រាហាំវិញ ដ្បិតអញបានតាំងឯងឱ្យធ្វើជាឪពុកនៃសាសន៍ជាច្រើន" លោកុប្បត្តិ ១៧:៥ ។ អ័ប្រាហាំមានន័យថា "ឪពុកនៃមនុស្សជាច្រើនអស្ចារ្យ" ។ ហើយនេះបង្កើតការសន្យា

ការសន្យាទូទាំងពិភពលោក

មនុស្សមកពីជាតិសាសន៍ណាក៏ដោយ នឹងក្លាយជាទាយាទនៃការសន្យា ប្រសិនបើគេទទួលយកផែនការរបស់ព្រះដោយផ្ទាល់ខ្លួនគេ ។ ពេត្រុសបាននិយាយពេលពេលគាត់ជ្រមុជទឹកឱ្យសាសន៍ដ៏ទៃជាលើកដំបូង.....

"ឥឡូវខ្ញុំដឹងប្រាកដច្បាស់ថា.....

ព្រះមិនរើសមុខអ្នកណាទេ.....

តែទទួលយកមនុស្សគ្រប់គ្នាពីគ្រប់ប្រទេសទាំងអស់ ដែលកោតខ្លាចទ្រង់ ហើយប្រព្រឹត្តសេចក្ដីសុចរិត។ អ្នកដឹងពីព្រះបន្ទូលដែលទ្រង់បានផ្សាយមកដល់ពួកជនសាសន៍អីស្រាអែល ដោយប្រកាសប្រាប់ដំណឹងល្អ ដោយសារព្រះយេស៊ូវគ្រីស្ទ ដ៏ជាព្រអម្ចាស់លើទាំងអស់" កិច្ចកា ១០:៣៤-៣៦។

លោកប៉ូលនិយាយយ៉ាងសាមញ្ញពីបញ្ហានេះនៅ កាឡាទី ៣:៧ "ចូរដឹងថា ពួកអ្នកដែលមានសេចក្ដីជំនឿ នោះជាពូជអ័ប្រាហាំហើយ "។ នៅក្នុងបន្ទាប់ទៀត គាត់បង្ហាញយើងថា ដំណឹងល្អពីនគរព្រះបង្រៀនដោយ ព្រះយេស៊ូវ និងសាវករបស់ទ្រង់ គឺផ្អែកលើការសន្យាចំពោះអ័ប្រាហាំ។ ទ្រង់មានបន្ទូលថា "ព្រះគម្ពីបានដឹងជាមុនថា ព្រះទ្រង់នឹងរាប់ពួកសាសន៍ដទៃជាសុចរិត បានជាមានសេចក្ដីប្រកាសមកដល់ លោកអ័ប្រាហាំជាមុនថា "អស់ទាំងសាសន៍នឹងបានពរដោយសារឯង "។

អ័ប្រាហាំបានបង្ហាញជំនឿអស្ចារ្យរបស់ទ្រង់ ដោយការជឿលើព្រះបន្ទូលព្រះ និងធ្វើសកម្មភាពពីជំនឿនោះ។ យើងអាននៅក្នុង ហេព្រើ ១១:៨-៩ " ដោយសារសេចក្ដីជំនឿ កាលព្រះបានហៅលោកអ័ប្រាហាំ នោះលោកក៏បានស្តាប់បង្គាប់ លោកចេញទៅឯកន្លែងដែលត្រូវទទួលជាមរដក គឺចេញទៅឥតមានដឹង ជាទៅឯណាទេ ដោយសារសេចក្ដីជំនឿ នោះលោកបានស្នាក់នៅក្នុងស្រុក ដែលទ្រង់សន្យាឱ្យ ដូចជានៅប្រទេសដទៃ ក៏នៅតែក្នុងត្រសាល ជាមួយនឹងអីសាក ហើយនឹងយ៉ាកុប ជាអ្នកគ្រងសេចក្ដីសន្យា ដដែល ទុកជា មរដកជាមួយគ្នា " ។

ក្នុងមួយជីវិតរបស់គាត់ អ័ប្រាហាំមិនដែលបាត់បង់ជំនឿលើព្រះទេ។ គាត់មិនបានទទួលបានទឹកដីសន្យាទេ។ ព្រះ "មិនបានប្រទាន ឱ្យលោកមានមរដកអ្វី នៅស្រុកនោះទេ សូម្បីឱ្យល្មមនឹងដាក់ជើងចុះក៏គ្មានដែរ តែទ្រង់ សន្យានឹងប្រទានស្រុកនោះ ទុកជាស្រុកកំណាន់ដល់លោក នឹងពូជលោកតទៅវិញ ថ្វីបើលោកមិនទាន់មានកូន នៅឡើយផង " កិច្ចកា ៧:៥។

នេះជាប្រភេទនៃជំនឿដែលព្រះសុំឱ្យយើងមាន។ នោះមិនមែនជាឈាមរបស់លោកអ័ប្រាហាំនៅក្នុងសរសៃឈាមយើងទេដែលចាំបាច់ តែជាសេចក្ដីជំនឿរបស់លោកអ័ប្រាហាំនៅក្នុងចិត្តរបស់យើង។ អ័ប្រាហាំ ជា..

អ្នកគ្រងមរដកនៃពិភពលោក

គឺ "...ជឿជាក់អស់ពីចិត្តថា ព្រះមានព្រះចេស្ដានឹងធ្វើឱ្យសំរេចបានអ្វីដែលទ្រង់បានសន្យា" រ៉ូម ៤:២១ (រ៉ូម ៤:១៣-២៥)។ ហើយព្រះជាពិតប្រាកដណាស់ថា នឹងធ្វើកិច្ចការនោះ ពេលដែលអ័ប្រាហាម នឹងត្រូវរស់ពីស្លាប់ឡើងវិញ ដើម្បីទទួលយកមរដកដែលបានសន្យា របស់គាត់នៅក្នុងនគរនៅអស់កល្បជានិច្ចរបស់ព្រះ។ ម៉ាកុស ១២:២៦ "ឯដំណើរដែលមនុស្សរស់ពីស្លាប់ឡើងវិញ នោះតើអ្នករាល់គ្នាមិនបានមើលពីរឿងគុម្ពបន្លា ដែលមាននៅក្នុងគម្ពីររបស់លោកម៉ូសេទេឬអី ដែលព្រះទ្រង់មានបន្ទូលនឹងលោកថា "អញជាព្រះនៃអ័ប្រាហាំ ជាព្រះនៃអីសាក ហើយជាព្រះនៃយ៉ាកុប ?" (មីកា ៧:២០)។ រាល់ពូជដែលស្មោះត្រង់របស់អ័ប្រាហាំ នោះនឹងនៅជាមួយគាត់នៅថ្ងៃនោះ។ ព្រះយេស៊ូវមានបន្ទូលដោយអង្គទ្រង់ថា "មានមនុស្សជាច្រើន ពីទិសខាងកើត និងទិសខាងលិច មកអង្គុយជាមួយនឹងលោកអ័ប្រាហាំ លោកអីសាក នឹងលោកយ៉ាកុប នៅក្នុងនគរស្ថានសួគ៌" ម៉ាថាយ ៨:១១ (លូកា ១៣:២៨-២៩)។
តើជំហ៊ានណាខ្លះដែលយើងត្រូវដើរ ដើម្បីទទួលបានកន្លែងមួយក្នុងចំនោមពួកបរិសុទ្ធដែលស្មោះត្រង់កាលពីសម័យដើម? ជាថ្មីម្ដងទៀត យើងត្រូវបាននាំមកកាន់ជំនឿ និងពិធីជ្រមុជទឹកដែលជាចំលើយ នោះគឺជាជំនឿ និងការស្ដាប់បង្គាប់ដោយបន្ទាប់ខ្លួន។

នៅកាឡាទី ៣:១៦ លោកប៉ូលបានប្រាប់យើងយ៉ាងសាមញ្ញថា.....

ព្រះគ្រីស្ទជាពូជរបស់អ័ប្រាហាំ.....

ព្រះពរដែលបានសន្យានឹងមកតាមរយៈទ្រង់។ ការសុគត និងការរស់ឡើងវិញកើតមាន "...ប្រយោជន៍នឹងបញ្ជាក់សេចក្ដីសន្យា ដែលបានតាំងនឹងពួកឰយុកោ" រ៉ូម ១៥:៨។

វាជាការគាប់ព្រះហឫទ័យដល់ព្រះក្នុងការធ្វើពិធីជ្រមុជទឹកជាផ្លូវសំរាប់មនុស្សទាំងប្រុស ស្រី មិនថាសាសន៍យូដា ឬសាសន៍ដទៃដោយការកើតជាថ្មី ក្លាយជាតែមួយជាមួយព្រះគ្រីស្ទ។ នេះជាអ្វីដែលលោកប៉ូលនិយាយក្នុង កាឡាទី ៣:២៦-២៩ "ដ្បិតអ្នករាល់គ្នាសុទ្ធតែជាកូនព្រះ ដោយសារសេចក្តីជំនឿដល់ព្រះគ្រីស្ទយេស៊ូវ ព្រោះអស់អ្នកណាដែលទទួលបុណ្យជ្រមុជក្នុងព្រះគ្រីស្ទ នោះឈ្មោះថាបានប្រដាប់កាយដោយព្រះគ្រីស្ទហើយ គ្មានសាសន៍យូដា ឬសាសន៍ក្រេក គ្មានបាវបំរើ ឬអ្នកជា គ្មានប្រុស នឹងស្រីទៀតទេ ពីព្រោះអ្នករាល់គ្នារួមមកតែមួយ នៅក្នុងព្រះគ្រីស្ទយេស៊ូវ ហើយបើអ្នករាល់គ្នាជារបស់ផងព្រះគ្រីស្ទ នោះក៏ពេញជាពូជរបស់លោកអ័ប្រាហាំ ហើយជា.....

អ្នកគ្រងមរដកតាមសេចក្តីសន្យា "

គ្មានសេចក្តីសង្ឃឹមសំរាប់មនុស្សណាដែលឃ្លាតចេញពី "ការសន្យាធំបំផុត ហើយវិសេស" ពេត្រុសទី២ ១:៤។ ទោះបី លោកនីកូដេម ជាចៅហ្វាយសាសន៍យូដារួចហើយក៏ដោយ ព្រះយេស៊ូវបានប្រាប់គាត់ថា គាត់ត្រូវតែ "កើតជាថ្មី" នោះគឺ "កើតពីទឹក និងព្រះវិញ្ញាណ" យ៉ូហាន ៣:១-៧។

យើត្រូវចង្អុលបង្ហាញឱ្យដឹងថា សេចក្តីសង្ឃឹមរបស់គ្រីស្ទបរិស័ទដំបូងគឺ......

សេចក្តីសង្ឃឹមនៃអីស្រាអែល.......

ដោយផ្អែកលើការសន្យារបស់ព្រះចំពោះអ័ប្រាហាំ និងដាវីឌ កិច្ចកា ១:៦ "ដូច្នេះ កាលពួកសាវ័កបានប្រជុំគ្នា នោះក៏ទូលសួរថា ព្រះអម្ចាស់អើយ តើនៅគ្រានេះឬអី ដែលទ្រង់នឹងតាំងនគរឱ្យសាសន៍អីស្រាអែលឡើងវិញនោះ? " លោកប៉ូល ពេលដែលគាត់ជាអ្នកទោសនៅពីមុខព្រះរាជាអ័គ្រីប៉ា និយាយថា "ហើយឥឡូវទូលបង្គំជាប់ជំនុំជំរះ នោះគឺដោយព្រោះតែមានចិត្តសង្ឃឹមដល់សេចក្តីសន្យាដែលព្រះបានតាំងនឹងពួកព្វយុកោទូលបង្គំ" កិច្ចកា ២៦:៦។ ក្រោយមក នៅពេលគាត់ថិតក្នុងចំនង នៅទីក្រុងរ៉ូម ប្រកាសថា "ហេតុនោះបានជាខ្ញុំអញ្ជើញអ្នករាល់គ្នាមក ដើម្បីឱ្យបានឃើញមុខ ហើយនឹងពិគ្រោះគ្នា ដ្បិតគឺព្រោះសេចក្តីសង្ឃឹមរបស់សាសន៍អីស្រាអែលហើយ បានជាខ្ញុំជាប់ច្រវាក់ដូច្នេះ" កិច្ចកា ២៨:២០។

ហើយលោកប៉ូល ដដែលដែលនិយាយថាប្រសិនបើយើងគ្មានព្រះគ្រីស្ទ យើងគ្មានសេចក្តីសង្ឃឹមទេ ហើយយើងក៏គ្មានព្រះ។ (អេភេសូ ២:១២) ហើយនោះជាអ្វីមួយដែលគ្រៀមក្រំ។ តាមរយៈពិធីជ្រមុជទឹក នៅក្នុងសេចក្តីស្លាប់របស់ព្រះគ្រីស្ទ ហើយអស់អ្នកដែល "ពីដើមនៅឆ្ងាយ បានមកជិតវិញ ដោយសារព្រះលោហិតព្រះគ្រីស្ទ " ខ១៣។ ហេតុនេះធ្វើឱ្យយើងមានសំនួរថា តើអ្វីជាពិធីជ្រមុជទឹក?

ពិធីជ្រមុជទឹកជាការកប់ចូលក្នុងទឹក

នៅក្នុងកិច្ចការ ៨ យើងត្រូវបានប្រាប់អំពីមនុស្សជាក់លាក់ម្នាក់ដែលទទួលពិធីជ្រមុជទឹកដោយ ភីលីព។ "នោះលោកបានបង្គាប់ឱ្យបញ្ឈប់រថ រួចភីលីព គាត់ធ្វើបុណ្យជ្រមុជទឹកឱ្យ លុះឡើងពីទឹកមក នោះព្រះវិញ្ញាណនៃព្រះអម្ចាស់ ទ្រង់ឆក់យកភីលីពបាត់ទៅ ហើយអ្នកកំរៀវមិនបានឃើញគាត់ទេ ក៏ទៅតាមផ្លូវទៅដោយអរសប្បាយ....." រ៉ូម ៨:៣៨-៣៩។ បន្ទាប់មកនៅក្នុង រ៉ូម ៦:៣-៤ យើងអានពាក្យរបស់លោកប៉ូល "តើអ្នករាល់គ្នាមិនដឹងទេឬអីថា យើងទាំងប៉ុន្មានដែលបានទទួលបុណ្យជ្រមុជក្នុងព្រះយេស៊ូវគ្រីស្ទ នោះគឺបានទទួលជ្រមុជក្នុងសេចក្តីសុគតនៃទ្រង់ដែរ ដូច្នេះ យើងបានត្រូវកប់ជាមួយនឹងទ្រង់ហើយ ដោយទទួលជ្រមុជក្នុងសេចក្តីស្លាប់ ដើម្បីឱ្យយើងបានដើរក្នុងជីវិតបែបថ្មី ដូចជាព្រះគ្រីស្ទបានរស់ពីស្លាប់ឡើងវិញ ដោយសារសិរីល្អនៃព្រះវបិតាដែរ "។

ការកប់ជាការគ្រប់បាំងដោយពេញលេញ។ នោះជួយឱ្យយើងយល់ពីអត្ថន័យនៃពិធីជ្រមុជទឹក ហើយនឹងអ្វីដែលពិធីជ្រមុជទឹកផ្តល់ឱ្យអ្នកដែលទទួលពិធីនោះ។

នៅពេលអ្នកណាម្នាក់ស្លាប់ពួកគេមិនធ្វើអំពើបាបទៀតទេ។ លោកប៉ូលបាននិយាចំនុចនៅក្នុង រ៉ូម ៦:៧ "ដ្បិតអ្នកណាដែលស្លាប់ នោះក៏រាប់ជាសុចរិតរួចពីបាបហើយ "។ ឥឡូវព្រះបានប្រាប់យើងថា បើយើងចង់ឱ្យព្រះសព្វព្រះហឫទ័យ យើងត្រូវតែសំលាប់និស្ស័យសាច់ឈាម នោះមានន័យថា យើងមិនត្រូវអនុញ្ញាតិឱ្យបំណងសាច់ឈាមរបស់យើងត្រួតត្រាលើយើង។
យើងត្រូវតែត្រួតត្រាលើវ។ យើងត្រូវតែកាត់ផ្តាច់ពួកវាចោល "ដាវនៃព្រលឹងវិញ្ញាណ គឺជាព្រះបន្ទូលព្រះ " អេភេសូ ៦:១៧ (ហេព្រើ ៤:១២)។

នេះជាសង្គ្រាមនៃជីវិតជាគ្រីស្ទបរិស័ទ។ នេះជាការការក្រក់ដែលយើងត្រូវតយុទ្ធ និងយកឈ្នះ។ "ដ្បិតសាច់ឈាមតែងតែប៉ងប្រាថ្នា ទាស់នឹងព្រះវិញ្ញាណ ឯព្រះវិញ្ញាណ ទ្រង់ក៏ទាស់នឹងសាច់ឈាមដែរ សេចក្តីទាំង២នេះប្រឆាំងនឹងគ្នា ដល់ម្លេះបានជាអ្នករាល់គ្នារកធ្វើការ ដែលចង់ធ្វើទៅមិនកើត " កាឡាទី ៥:១៧។ លោកប៉ូល បានបន្តនិយាយនៅ ខ២៤ ថា "ហើយអស់អ្នកដែលជារបស់ព្រះគ្រីស្ទ នោះបានឆ្កាងសាច់ឈាមហើយ ព្រមទាំងសេចក្តីរំជួល នឹងសេចក្តីប៉ងប្រាថ្នា ទាំងប៉ុន្មានផង "។ គាត់ក៏បានសរសេរម្តងទៀតថា "ចូរសំលាប់និស្ស័យសាច់ឈាមរបស់អ្នករាល់គ្នា ដែលនៅផែនដីនេះចេញ " កូល៉ុស ៣:៥។

ពិធីជ្រមុជទឹកជាការកប់អ្វីដែលនៅក្នុងគំនិតរបស់មនុស្សដែលត្រូវស្លាប់ខាងអំពើបាប ហើយត្រូវចាប់ផ្តើមជីវិតថ្មីក្នុងព្រះគ្រីស្ទ។ ដូច្នេះ លោកប៉ូលនិយាយ "ចូរអ្នករាល់គ្នារាប់ខ្លួនទុកជាស្លាប់ខាងបាបដែរ តែរស់ខាងឯព្រះវិញចុះ " រ៉ូម ៦:១១។

ពិធីជ្រមុជទឹកជាការចាប់ផ្តើមដំបូងនៃ

ជីវិតថ្មី

នៅពេលមនុស្សម្នាក់ត្រូវបានជ្រមុជទឹក ដូចដែលយើងបានឃើញមកហើយ គាត់ "កើតម្តងទៀត " យ៉ូហាន ៣:៣ ៥ ៧ (ពេត្រុសទី១ ១:២៣) មិនមែនផ្នែករាងកាយទេ តែផ្នែកគំនិត។ ដូចជា ទារកដែលទើបនឹងកើតថ្មី គាត់ចំរើនធំឡើងដោយសារ "ទឹកដោះសុទ្ធនៃព្រះបន្ទូល " ពេត្រុសទី១ ២:២។

មុនពេលទទួលពិធីជ្រមុជទឹក គេគឺ "ក្នុងអ័ដាម" តែបន្ទាប់ពីពិធីជ្រមុជទឹក គេគឺ "ក្នុងព្រះគ្រីស្ទ "។ លោកប៉ូលសរសេរនៅក្នុង កូរិនថូសទី២ ៥:១៧ "បានជាបើអ្នកណានៅក្នុងព្រះគ្រីស្ទ នោះឈ្មោះថាបានកើតជាថ្មីហើយ អស់ទាំងសេចក្តីចាស់កន្លងបាត់ទៅ មើលគ្រប់ទាំងអស់បានត្រឡប់ជាថ្មីវិញ "។ អ្នកជឿដែលស្តាប់បង្គាប់គឺនៅតែជាមនុស្សដែលស្លាប់។ តែគេឥឡូវជា**អ្នកគ្រងមរដកនៃជីវិតអស់កល្ប** (រ៉ូម ៨:១៧ ទិតុស ១:២)។ គេជា **កូនស្ងួនភ្ងានៃព្រះ** តាមរយៈជាកូនចិញ្ចឹម (យ៉ូហាន ១:១២ រ៉ូម ៨:១៤-១៩ ហេព្រើ ២:១០) ហើយជា បងប្អូនរបស់ព្រះអម្ចាស់យេស៊ូវគ្រីស្ទ។ គេជាសមាជិកគ្រួសារព្រះ។ ទំនាក់ទំនងនេះអាចបង្ហាញដោយពាក្យ ជាឈ្មោះថា

បងប្អូនក្នុងព្រះគ្រីស្ទ (Christadelphian).....

.....ដែលមានន័យថា **បងប្អូនរបស់ ព្រះគ្រីស្ទ** ។ ពាក្យនេះជាឈ្មោះព្រះគ្រីស្ទ និងពាក្យបងប្អូនជាភាសាក្រិច លាយបញ្ចូលក្លាយជាពាក្យតែមួយ ។ ព្រះយេស៊ូវមិនខ្មាស់នឹងហៅគេថាជាបងប្អូនទេ ដ្បិតអ្នកណាធ្វើតាមព្រះហឫទ័យនៃព្រះវបិតាខ្ញុំដែលនៅស្ថានសួគ៌ (ហេព្រើ ២:១១ ម៉ាថាយ ១២:៥០) ។

អ្នកណាដែលគោរពតាមដំណឹងល្អ (តាមរយៈពិធីជ្រមុជទឹក) មានសេចក្តីសង្ឃឹមថ្មី គំនិតថ្មី ឥរិយាបថថ្មី និងគោលបំណងថ្មីក្នុងការរស់នៅ ។ គោលដៅចំបងនៃជីវិតនេះគឺ

ស្វែងរកនគរព្រះ.....

និងសេចក្តីសុចរិតនៃព្រះជាមុនសិន ទើបគ្រប់ទាំងរបស់ទាំងនោះ នឹងបានប្រទានមកអ្នករាល់គ្នាថែមទៀតផង" ម៉ាថាយ ៦:៣៣ ។ មនុស្សគ្រប់រូបគួរមានគោលបំណងក្នុងជីវិត ។ ការគ្មានគោលដៅគឺរសាត់តាមខ្សែទឹក ។ មនុស្សឆ្លាតគេនឹងយកនគរព្រះជាគោលដៅរបស់គេ ។

យើងដឹងហើយថាមានតែតាមរយៈ "ជំនឿ " ដែលមនុស្សមានបាបអាចចូលរួមជាមួយអ្នកដែល "ត្រូវបានហៅ អ្នកបរិសុទ្ធ " រ៉ូម ១:៧ ។ ប៉ុន្តែ "ការងារ" ក៏ត្រូវការជាចាំបាច់ដើម្បីឱ្យដឹងប្រាកដពីការទទួលយករបស់ពួកអ្នកបរិសុទ្ធ នៅថ្ងៃព្រះអម្ចាស់យាងមក ។

"ជំនឿដោយគ្មានការប្រព្រឹត្តក៏គ្មានប្រយោជន៍ " យ៉ាកុប ២:២០

"ការងារ" ដែលព្រះតំរូវឱ្យធ្វើគឺការរក្សា **បញ្ញត្តរបស់ព្រះគ្រីស្ទ** ។ ការអានពីការងាររបស់ព្រះនឹងជួយឱ្យយើង ដឹង យល់ និងចង់ចាំពីបញ្ញត្តទាំងនោះ ។ ដូចជា "ក្រិត្យវិន័យ និងទំនាយ " ត្រូវបានបង្រួមមកតែច្បាប់ ជាមូលដ្ឋានចំបងពីរ : "ស្រលាញ់ដល់ព្រះអម្ចាស់នៃឯង ឱ្យអស់ពីចិត្ត អស់ពីព្រលឹង អស់ពីគំនិត ហើយអស់ពី កំឡាំងនៃឯង" នោះហើយជាបញ្ញត្តទី១ ឯបញ្ញត្តទី២ ក៏បែបដូចគ្នា គឺថា "ត្រូវស្រលាញ់អ្នកជិតខាង ដូចខ្លួនឯង" ម៉ាកុស ១២:៣០-៣១ ។

"សេចក្តីស្រលាញ់ជាការបំពេញឱ្យក្រិត្យវិន័យ" រ៉ូម ១៣:១០

សេចក្តីស្រលាញ់របស់យើងចំពោះព្រះ និងមនុស្ស គឺកើតមានដោយសារហេតុផលមួយ "យើងស្រលាញ់ ពីព្រោះទ្រង់បានស្រលាញ់យើងជាមុន " យ៉ូហានទី១ ៤:១៩ ។ ប្រសិនបើយើងស្រលាញ់ព្រះវបិតា យើងមិនស្រលាញ់លោកិយ នៅក្នុងរបៀបមួយនៃការរស់នៅ ឬចង់បានរបៀបនៃលោកិយ ។ លោក យ៉ាកុប សួរថា "ឱពួកកំផិតទាំងប្រុសទាំងស្រីអើយ តើមិនដឹងទេឬអីថា ដែលស្រលាញ់ដល់លោកិយ នោះគឺស្អប់ដល់ ព្រះហើយ ដូច្នេះ អ្នកណាដែលចូលចិត្តចង់ធ្វើជាមិត្រសំឡាញ់នឹងលោកិយ នោះឈ្មោះថា បានតាំងខ្លួនជាខ្មាំង សត្រូវនឹងព្រះវិញ " យ៉ាកុប ៤:៤ ។

លោក យ៉ូហានបង្ហាញពីបញ្ហាយ៉ាងច្បាស់នៅពេលគាត់សរសេរថា

"កុំឱ្យស្រលាញ់លោកីយ.......

.......ឬរបស់អ្វីដែលនៅក្នុងលោកីយនេះឱ្យសោះ បើអ្នកណាស្រលាញ់លោកីយ អ្នកនោះគ្មានសេចក្តីស្រលាញ់ របស់ព្រះវបិតានៅក្នុងខ្លួនឡើយ ដ្បិតអស់ទាំងសេចក្តី ដែលនៅក្នុងលោកីយនេះ គឺជាសេចក្តីប៉ងប្រាថ្នារបស់ សាច់ឈាម នឹងសេចក្តីប៉ងប្រាថ្នារបស់ភ្នែក ហើយសេចក្តីអំនួតរបស់ជីវិតនោះមិនកើតមកពីព្រះវបិតាទេ គឺមកតែពីលោកីយនេះវិញ ឯលោកីយនេះ នឹងសេចក្តីប៉ងប្រាថ្នារបស់វានោះកំពុងកន្លងទៅ តែអ្នកណាដែល ធ្វើតាមព្រះហឫទ័យព្រះ នោះនឹងនៅជាប់អស់កល្បជានិច្ចវិញ " យ៉ូហានទី១ ២:១៥-១៧ ។

មនុស្សគ្រប់គ្នាគួរពិចារណាដោយប្រុងប្រយ័ត្នពីពាក្យទាំងនេះ ។

នៅយប់ដែលទ្រង់ត្រូវបានគេក្បត់នោះ ព្រះយេស៊ូវបានអធិស្ឋានសំរាប់បងប្អូនរបស់ទ្រង់ក្នុងរបៀបដូច្នេះ។ ទ្រង់នឹងត្រូវចាកចេញពីពួកគេក្នុងពេលឆាប់ៗ។ "ទូលបង្គំមិនសូមឱ្យយកគេចេញពីលោកីយទេ គឺសូមឱ្យទ្រង់រក្សាគេ ឱ្យរួចពីសេចក្តីអាក្រក់វិញ គេមិនមែនជារបស់ផងលោកីយ ដូចជាទូលបង្គំក៏មិនមែនជារបស់លោកីយដែរ សូមញែកគេចេញជាបរិសុទ្ធ ដោយសារសេចក្តីពិតរបស់ទ្រង់ " យ៉ូហាន ១៧:១៥-១៣។

ហេតុដូចនេះហើយ ទីតាំងនៃការរស់នៅរបស់រាស្ត្រព្រះរង់ចាំការយាងមកនៃស្តេចរបស់គេគួរតែនៅ**ក្នុង** លោកីយ តែ**មិនមែនជារបស់លោកីយទេ**។ ទាមរយៈការបង្រៀនព្រះបន្ទូលដ៏មានសិរីល្អរបស់ទ្រង់ ព្រះកំពុងតែទតមើលសាសន៍ដទៃ "ដើម្បីរើសយក....

រាស្ត្រមួយសំរាប់ព្រះនាមទ្រង់ " កិច្ចការ ១៥:១៤

ដំណឹងល្អគឺជាការត្រាសហៅឱ្យញែកខ្លួនឱ្យដាច់ដោយឡែក។ ដូចដែលព្រះបានត្រាសហៅ អ័ប្រាហាំ "ចេញមក " ដូច្នេះហើយអស់អ្នកណាដែលជាកូនទ្រង់ ទ្រង់ក៏នៅតែនិយាយថា "ចូរចេញពីកណ្តាលពួកគេទៅ ហើយញែកខ្លួនទៅដោយឡែក កុំឱ្យពាល់របស់ស្មោកគ្រោកឡើយ នោះអញនឹងទទួលឯងរាល់គ្នា អញនឹងធ្វើជាឪពុកដល់ឯងរាល់គ្នា ហើយឯងរាល់គ្នានឹងធ្វើជាកូនប្រុសកូនស្រីដល់អញ នេះជាព្រះបន្ទូលនៃព្រះអម្ចាស់ដ៏មានព្រះចេស្តាបំផុត " កូរិនថូសទី២ ៦:១៧-១៨។

អស់អ្នកដែលស្តាប់បង្គាប់ការត្រាស់ហៅរបស់ព្រះ "ចេញមក" នឹងមិនមែនចំនែកនៅក្នុង.....

កិច្ចការនយោបាយ និងនាហ៊ាន....

នៃលោកីយដ៏អាក្រក់សព្វថ្ងៃនេះ។ (កាឡាទី ១:៤)។ ពួកគេអធិស្ឋានជារៀងរាល់ថ្ងៃ ហើយរង់ចាំនគរព្រះដែលនឹងបំបែករបស់ដែលមានរបៀបរៀបរយដែលមានស្រាប់នោះជាផ្នែកតូចៗ។

អាពាហ៍ពិពាហ៍

ដោយយោងទៅតាមបញ្ញត្ត "កុំទឹមនឹមស្រៀក ជា១មនុស្សមិនជឿឡើយ " កូរិនថូសទី២ ៦:១៤ ពួកគេរៀបការ "តែនៅក្នុងព្រះអម្ចាស់ " កូរិនថូសទី១ ៧:៣៩។ ពួកគេចាត់ទុកការសន្យាអាពាហ៍ពិពាហ៍ ជាការចងភ្ជាប់រហូតថ្ងៃស្លាប់ ឬការយាងមករបស់ព្រះអម្ចាស់។ ម៉ាថាយ ៥:៣២ "ប៉ុន្តែ ខ្ញុំប្រាប់អ្នករាល់គ្នាថា ស្ត្រីណាដែលមិនផិតប្តី បើប្តីនោះលែងចេញ នោះឈ្មោះថា បានធ្វើឱ្យនាងទៅជាស្រីសំផឹងហើយ បើអ្នកណាយកស្ត្រីដែលប្តីលែង ធ្វើជាប្រពន្ធ អ្នកនោះហៅថា ប្រព្រឹត្តសេចក្តីកំផិតដែរ "។

ពួកគេជៀសវាងទំលាប់ និងការរីករាយជាច្រើននៃសង្គមដែលគ្មានព្រះជុំវិញពួកគេ នៅក្នុងចំនោមអ្វីដែល ពួកគេត្រូវបានបង្គាប់ឱ្យភ្លឺដូចជាពន្លឺ "តែអ្នករាល់គ្នាជាពូជជ្រើសរើស ជាពូជសង្ឃហ្លួង ជាសាសន៍បរិសុទ្ធ ជារាស្ត្រកេរ្តិ៍អាករនៃព្រះ ដើម្បីឱ្យអ្នករាល់គ្នាបានសំដែងចេញ ឱ្យឃើញអស់ទាំងលក្ខណៈរបស់ព្រះ ដែលទ្រង់ បានហៅអ្នករាល់គ្នាចេញពីសេចក្តីងងឹត មកក្នុងពន្លឺអស្ចារ្យរបស់ទ្រង់ " ពេត្រុសទី១ ២:៩ (ម៉ាថាយ ៥:១៤) ។

អាហារពេលល្ងាចចងចាំ

ជារៀងរាល់ថ្ងៃដំបូងនៃសប្តាហ៍នីមួយៗ អ្នកដើរតាមអង្គព្រះយេស៊ូវគ្រីស្ទដែលជ្រមុជទឹកហើយប្រជុំគ្នាដើម្បី ថ្វាយបង្គំព្រះវបិតា ហើយចងចាំបុត្រារបស់ទ្រង់ តាមរបៀបដែលព្រះគម្ពីបានបង្ហាញដោយការញ៉ាំនំប៉័ងដែល បានកាច់ (និមិត្តសញ្ញាឱ្យរូបកាយរបស់ទ្រង់) និងផឹកស្រាទំពាំងបាយជូរដែលបានកាច់ (តំណាងឱ្យឈាម ដែលបានបង្ហូរ) ។ អ្នកជឿធ្វើបែបដូច្នេះ ដូចជាការចងចាំពីក្តីស្រលាញ់នៃការបូជារបស់ទ្រង់ និងដើម្បីអបអរ ជោកជ័យរបស់ទ្រង់លើសេចក្តីស្លាប់..... "រួចទ្រង់ក៏យកនំប៉័ងមកអរព្រះគុណ ហើយកាច់ប្រទានទៅគេ ដោយបន្ទូលថា នេះហើយជារូបកាយខ្ញុំ ដែលបានប្រទានមកសំរាប់អ្នករាល់គ្នា ចូរធ្វើបុណ្យនេះ ដើម្បីរំឮកពីខ្ញុំ ចុះ ក្រោយដែលបានបរិភោគហើយ នោះទ្រង់យកពែងធ្វើបែបដូច្នោះដែរ ដោយបន្ទូលថា ពែងនេះជាសញ្ញាថ្មី ដែលតាំងដោយនូវឈាមខ្ញុំ គឺជាឈាមដែលត្រូវច្រួចចេញសំរាប់អ្នករាល់គ្នា " លូកា ២២:១៩-២០ (កូរិនថូសទី១ ១១:២៣-២៩) ។

តាមរយៈការធ្វើបែបដូច្នោះ អ្នកជឿដើរតាមសាវ័ក "លុះថ្ងៃដំបូងក្នុងអាទិត្យនោះ កាលពួកសិស្សបានប្រជុំគ្នា ដើម្បីកាច់នំបុ័ង..... " កិច្ចកា ២០:៧។ អ្នកដើរតាមអង្គព្រះយេស៊ូវគ្រីស្ទ ".....ព្យាយាមក្នុងសេចក្តីបង្រៀន របស់ពួកសាវ័ក ហើយក្នុងសេចក្តីប្រកបគ្នា ព្រមទាំងការកាច់នំបុ័ង នឹងសេចក្តីអធិស្ឋានផង " កិច្ចកា ២:៤២ រីករាយនឹងឃើញទីសំគាល់ជាច្រើន ដែលធ្វើឱ្យជំនឿរបស់ពួកគេកាន់តែរឹងមាំ ព្រោះការយាងមកនៃ ព្រះអម្ចាស់កាន់តែជិតមកដល់ហើយ។

ពីមួយថ្ងៃទៅមួយថ្ងៃ "ឥតលែងប្រជុំគ្នា ដូចជាអ្នកខ្លះធ្លាប់នោះឡើយ ត្រូវឱ្យកំឡាចិត្តគ្នាវិញ ឱ្យកាន់តែខ្លាំង ឡើងផង តាមដែលឃើញថាថ្ងៃនោះជិតមកដល់ហើយ "ហេព្រើ ១០:២៥។

ខណៈដែលមានកិច្ចការជាច្រើនដែលត្រូវធ្វើនៅក្នុងផ្នែកនេះ។ នោះគឺត្រូវ......

កសាខនូតចរិកលកូឈះ....

ការមានតំលៃនៃនគរដ៏អស្ចារ្យ ដែលសេចក្តីសង្ឃឹមដំណឹងល្អនៅពីមុខយើង។ ព្រះយេស៊ូវមានបន្ទូលថា "អ្នកណាដែលដាក់ដៃកាន់នង្គ័ល ហើយងាកបែរទៅមើលក្រោយ អ្នកនោះមិនគួរនឹងនគរព្រះទេ " លូកា ៩:៦២។ ពេលដែលចាប់ផ្តើមហើយ នឹងមិនត្រូវថយក្រោយទេ។

យើងទទួលបានមេរៀនសំខាន់មួយពីប្រវត្តិសាស្ត្រអំពីរាស្ត្រពីដើមរបស់ព្រះ អ៊ីស្រាអែល។ ពួកគេត្រូវបាន ត្រាស់ហៅឱ្យចេញពីចំនងដ៏ងងឹតរបស់ពួកអេស៊ីព្ទ ដើម្បីដើរទៅកាន់ទឹកដីសន្យា។ ព្រះបានដឹកនាំគេឆ្លងកាត់ វាលរហោស្ថាន។ នោះជាពេលមួយនៃការសាកល្បងរបស់ពួកគេ ពួកគេបានត្រលប់ក្រោយ នៅក្នុងចិត្តរបស់ គេទៅចំពោះអ្វីដែលគេធ្លាប់មានពីមុន (ជនគណនា ១៤:៤)។ ហើយជាលទ្ធផល ពួកគេមិនបានសំរេច គោលបំណងគេទេ។

ឥឡូវសូមអានអ្វីដែលលោកប៉ូលនិយាយអំពីការនេះនៅក្នុង កូរិនថូសទី១ ១០:១-១១។ ហើយសូមអាន យូដាស ខ ៥ ដែលទ្រង់រំលឹកយើងថា "ដែលព្រះអម្ចាស់បានជួយសង្គ្រោះរាស្ត្រទ្រង់ ឱ្យរួចពីស្រុកអេស៊ីព្ទមក នោះទ្រង់បានបំផ្លាញពួកអ្នកដែលមិនជឿវិញ "។

ពិធីជ្រមុជទឹក មិនគ្រប់គ្រាន់នៅឡើយទេ។ មានសុភាសិតមួយនិយាយថា "ដំណើររាប់ពាន់គីឡូម៉ែត្រ ចាប់ផ្តើមពីមួយជំហ៊ាន "។ ជំហ៊ានដំបូងនេះគឺសំខាន់ តែមិនទាន់ជាការធ្វើដំណើរពេញលេញនៅឡើយទេ។ ត្រូវតែឆ្លងកាត់ជាច្រើនជំហ៊ានទៀត។

ពិធីជ្រមុជទឹកជាជំហ៊ានដំបូងនៃការធ្វើដំណើរទៅកាន់នគរព្រះ។ ក្នុង ហេព្រើ ៦:១ យើងអាន "ដូច្នេះ ចូរឱ្យយើងឈប់ ខាងសេចក្តីបថមសិក្សានៃព្រះបន្ទូលព្រះគ្រីស្ទ......

ចូរឱ្យយើងបន្តដល់សេចក្តីពេញខ្នាត "

នេះជាអ្វីដែលយើងត្រូវបានត្រាស់ហៅ ឱ្យក្លាយជាគោលដៅក្នុងជីវិតរបស់យើងក្នុងការដើរតាមអង្គព្រះយេស៊ូវគ្រីស្ទ។ អង្គទ្រង់ជាគំរូខ្នាតរបស់យើង។ មិនត្រឹមតែ ទ្រង់បាន "រងទុក្ខជំនួសយើងដែរ ទាំងទុកដំរាប់ ឱ្យយើងរាល់គ្នាដើរតាមលំអានដាននៃទ្រង់ " ពេត្រុសទី១ ២:២១ ហើយទ្រង់ជារាល់ថ្ងៃជួយយើងឱ្យដើរតាមផ្លូវនៃការស្តាប់បង្គាប់។ ហើយព្រះវបិតាជួយយើងតាមរយៈព្រះរាជបុត្រាទ្រង់។

លោកប៉ូល និយាយចំនុចនោះក្នុងការងារកសាង "ដ្បិតយើងរាល់គ្នាជាអ្នកធ្វើការជាមួយនឹងព្រះ " កូរិនថូសទី១ ៣:៩។ នេះជាភាពជាដៃគូរមួយ ! តើវាអាចបរាជ័យដោយរបៀបណា ទាល់តែយើងខ្លួនឯងបានបរាជ័យ?

ការងារដ៏អស្ចារ្យនៃការកសាងចរិកលក្ខណៈឱ្យល្អដែលសព្វហឬទ័យព្រះនោះទាមទារឱ្យមានទាំងការបោះចោល និងការបន្ថែមឱ្យមាន។ យើងត្រូវតែបោះចោលការងាររបស់ "មនុស្សចាស់ " ខាងសាច់ឈាម។ អេភេសូ ៤:២២-៣១ ។ "តែឥឡូវ ចូរឱ្យអ្នករាល់គ្នាលះអស់ទាំងអំពើនោះ គឺសេចក្តីកំហឹង គ្នាន់ក្នាញ់ គំរក់ ប្រមាថ នឹងពាក្យអព្វមង្គល ចេញពីមាត់ចោលទៅ កុំឱ្យកុហកគ្នាឡើយ ដ្បិតអ្នករាល់គ្នាបានដោះមនុស្សចាស់ នឹងអំពើរបស់វាចោលចេញហើយ " កូល៉ុស ៣:៨-៩។

ពាក្យព្រមានស្រាលមួយនៅទីនេះ ការងារក្នុងការធ្វើឱ្យដូចព្រះគ្រីស្ទ គឺជាការងារមួយដែលនាំឱ្យយើងនូវការកាត់ទោស និងការឈឺចាប់ (យ៉ូហានទី១ ៣:២ និង ភីលីព ៣:២០-២១) ។
"កាលទ្រង់ចង់នាំកូនជាច្រើនមកក្នុងសិរីល្អ នោះគួរគប្បីឱ្យទ្រង់បានធ្វើឱ្យផ្ទៃមេឃនៃសេចក្តីសង្គ្រោះគេបាន....

គ្រប់លក្ខណ៍ដោយទុក្ខលំបាក

"កូនជាច្រើន" មិនអាចរំពឹងទុកថាត្រូវបាន "ធ្វើឱ្យគ្រប់លក្ខណ៍ " ដោយវិធីផ្សេងទៀតក្រៅពីព្រះធ្វើការនេះជាមួយបុត្រារបស់ទ្រង់ទេ ។ មាសត្រូវបន្សុកដោយភ្លើង ។ ត្បូងស្អាតដោយសារការដុសខាត់ ។ ថ្មរស់ដែលបង្កើតបានជាវិហារព្រលឹងវិញ្ញាណរបស់ព្រះត្រូវតែរៀបចំឱ្យមានរូបរាង ។ (ពេត្រុសទី១ ២:៥-៦)
"ព្រះយេស៊ូវអង្គទ្រង់ " ជា "ថ្មជ្រុងយ៉ាងឯក " នៃអគារដ៏ល្អនោះ ។ អេភេសូ ២:២០-២១ ហើយ "ថ្ម" ផ្សេងទៀតត្រូវផ្សារភ្ជាប់គ្នាដែរ ។

"ពួកស្ងួនភ្ងាអើយ កុំឱ្យមានប្លែកក្នុងចិត្ត ដោយភ្លើងដ៏ក្តៅក្រហាយ ដែលកំពុងតែល្បងអ្នករាល់គ្នា ទុកដូចជាកើតមានសេចក្តីចំឡែកនោះឡើយ ត្រូវអរសប្បាយវិញ ដោយព្រោះមានចំណែកក្នុងការរងទុក្ខរបស់ព្រះគ្រីស្ទ ដើម្បីឱ្យអ្នករាល់គ្នាបានត្រេកអររីករាយជាខ្លាំងក្នុងកាលដែល**សិរីល្អទ្រង់លេចមក** " ពេត្រុសទី១ ៤:១២-១៣ ។ យើងត្រូវការជំនឿបែបនោះ ដូចជាអ័ប្រាហាំដើម្បីជួយគាំទ្រយើងឆ្លងកាត់ពេលវេលានៃការសាកល្បង ។ ដោយនូវការមើលឃើញជំនឿ ដោយយើងត្រូវតែមានចក្ខុវិស័យវែងឆ្ងាយ ហើយមិនត្រូវអស់សង្ឃឹមឡើយ ។ យើងប្រាកដច្បាស់ណាស់ថា "ក្នុងគ្រប់ការទាំងអស់ " ទោះបីជាការនោះហាក់ដូចជាពិបាកទ្រាំទ្រ "យើងដឹងថា គ្រប់ការទាំងអស់ផ្សំគ្នា សំរាប់សេចក្តីល្អដល់ពួកអ្នកដែលស្រលាញ់ព្រះ គឺដល់ពួកអ្នកដែលទ្រង់ហៅមក តាមព្រះដ៏រិះទ្រង់ " រ៉ូម ៨:២៨ ។

នោះជាការមួយឆ្លាតដែលត្រូវ....

គិតពីការខាតបង់

លោកសាវ័កប៉ូល ជាកូនព្រះដែលទ្រាំទ្រយ៉ាងខ្លាំងនៅក្នុងការសាកល្បងដែលឈឺចាប់។ ហើយនេះជាការសង្ខេបរបស់គាត់ "ខ្ញុំរាប់ទាំងសេចក្តីទុក្ខលំបាកនៅជាន់នេះ ថាជាសេចក្តីមិនគួរប្រៀបផ្ទឹមនឹងសិរីល្អ ដែលនឹងបើកសំដែង មកឱ្យយើងរាល់គ្នាឃើញនោះទេ " រ៉ូម ៨:១៨។ "ដ្បិតសេចក្តីទុក្ខលំបាកយ៉ាងស្រាលរបស់យើងខ្ញុំ ដែលនៅតែមួយភ្លែតនេះ នោះបង្កើតឱ្យយើងខ្ញុំមានសិរីល្អយ៉ាងធ្ងន់លើសលប់ដ៏នៅអស់កល្បជានិច្ចវិញ ដោយយើងខ្ញុំរាប់អានរបស់ដែលមើលមិនឃើញវិញ ដ្បិតរបស់ដែលមើលឃើញនោះស្ថិតស្ថេរមិនយូរទេ តែឯរបស់មើលមិនឃើញ នោះនៅស្ថិតស្ថេរអស់កល្បជានិច្ចវិញ " កូរិនថូសទី២ ៤:១៧-១៨។ (ហេព្រើ ១១:១)

មិនត្រូវភ្លេចសំនួរដែលអង្គព្រះគ្រីស្ទបានសួរមនុស្ស "ដ្បិតមនុស្សណានឹងមានលោកីយទាំងមូល តែបាត់ព្រលឹងទៅ នោះតើមានប្រយោជន៍អ្វីដល់អ្នកនោះ? " ម៉ាថាយ ១៦:២៦។ មនុស្សម្នាក់បូកឱ្យពិភពលោកទាំងមូល តែដកជីវិតគេចេញ តើស្មើអ្វី? ចំលើយនោះគឺសាមញ្ញ។ សូមធ្វើការដោះស្រាយចំនោទមួយនេះ។ ក្នុងការដោះស្រាយរកចំលើយ អ្នកនឹងរកឃើញ **តំលៃ** ពិតប្រាកដមួយ។

ក្នុងការពិនិត្យមើលកិច្ចការទាំងអស់នេះ វាសារៈមានសារៈសំខាន់ប៉ុណ្ណោះគឺ **ក្រោយពិធីជ្រមុជទឹក** យើងរក្សាគំរូរបស់ព្រះគ្រីស្ទពីមុខគំនិតរបស់យើង និងសិក្សាពីព្រះបន្ទូលដ៏មានតំលៃរបស់ព្រះវបិតានៅស្ថានសួគ៌ ហើយចូលទៅកាន់ "បល្ល័ង្កនៃព្រះគុណ " តាមរយៈការអធិស្ថាន តាមរយៈសំដេចសង្ឃដ៏ខ្ពស់បំផុតដែលទ្រង់បានចាត់មក។ (ហេព្រើ ៤:១៤-១៥ យ៉ូហានទី១ ២:១)។

ទំនុកដំកើង ១១៩:៩៧-៩៩ "ឱទូលបង្គំស្រលាញ់ក្រិត្យវិន័យរបស់ទ្រង់ណាស់ ទូលបង្គំរំពឹងគិតពីក្រិតវិន័យនោះជាដរាបរាល់ថ្ងៃ សេចក្តីបង្គាប់របស់ទ្រង់ ក៏ធ្វើឱ្យទូលបង្គំមានប្រាជ្ញា លើសជាងខ្មាំងសត្រូវ ដ្បិតបាននៅជាប់ជាមួយទូលបង្គំជាដរាប ទូលបង្គំមានយោបល់ជាងអស់ទាំងគ្រូ របស់ទូលបង្គំទៅទៀត ដ្បិតសេចក្តីបន្ទាល់ទ្រង់ជាទីនឹករំពឹងរបស់ទូលបង្គំ "។

ដូចគ្នាផងដែរនៅ ធីម៉ូថេទី២ ៣:១៦-១៧ "គ្រប់ទាំងបទគម្ពី គឺជាព្រះទ្រង់បានបញ្ចេញព្រះវិញ្ញាណឱ្យតែងទេ ក៏មានប្រយោជន៏សំរាប់ការបង្រៀន ការរំឭកឱ្យដឹងខ្លួន ការប្រដៅដំរង់ នឹងការបង្ហាត់ខាងសេចក្តីសុចរិត ដើម្បីឱ្យអ្នកសំណប់របស់ព្រះបានគ្រប់លក្ខណ៏ ហើយបានគ្រប់ទាំងចំណេះសំរាប់នឹងធ្វើការល្អគ្រប់មុខ។

- ដើម្បីរៀនពីអ្វីដែលត្រឹមត្រូវ
- ដើម្បីរៀនពីអ្វីដែលមិនត្រឹមត្រូវ
- របៀបដើម្បីធ្វើឱ្យត្រឹមត្រូវ និង
- ធ្វើដោយត្រឹមត្រូវ

នោះជាផ្នែកមួយនៃផែនការរបស់ព្រះជាមួយមនុស្ស ដែលរាស្ត្ររបស់ទ្រង់ត្រៀមរួចជាស្រេច "ត្រៀមមនុស្សមួយពួករួចជាស្រេចសំរាប់ព្រះអម្ចាស់ " លូកា ១:១៧។

ពាក្យមួយម៉ាត់ចុងក្រោយ

ពេលវេលាកាន់តែខ្លីហើយ។ ពិភពលោកយើងសព្វថ្ងៃថិតលើការផ្លាស់ប្តូរដ៏ធំមួយ។ នេះជា**ឱកាសរបស់អ្នក**! "ឥឡូវនេះជាវេលាដែលគាប់ព្រះហឬទ័យទ្រង់ " (កូរិនថូសទី២ ៦:២)។

មានតែបច្ចុប្បន្នកាលនេះទេដែលជារបស់យើង។ អតីតកាលបានកន្លងផុតហើយ ហើយអនាគតមិនទាន់មកដល់។ ហើយ "ជីវិតអ្នករាល់គ្នាជាអ្វី? គឺជាចំហាយទឹកទេតើ ដែលឃើញតែ១ភ្លែតរួចបាត់ទៅ " យ៉ាកុប ៤:១៤។

ជាថ្មីម្តងទៀត "អ្នកមិនដឹងជាថ្ងៃស្អែកកើតមានការអ្វីទេ " សុភាសិត ២៧:១។ យើងមានជីវិតរសាតអណ្តែតបច្ចុប្បន្ននេះ ដោយមានការគំរាមកំហែងដ៏ស្រាវមួយ។ ត្រូវមានប្រាជ្ញា។ ព្រះប្រទានឱ្យអ្នកនៅវេលាមួយ

សំរាប់គោលបំណងមួយ ។ សូមប្រើប្រាស់ឱ្យមានប្រយោជន៏ពេញលេញ ខណៈដែលយើងមានជីវិតនោះ ។ សូមប្រើវាដូចជាស្ពានចំលងទៅកាន់របស់ដែលអស្ចារ្យ ។ ការនោះអាចនាំទៅកាន់ជីវិតអស់កល្បជានិច្ចដែលពេញដោយអំណរ ។

"នៅវេលាដែលគាប់ចិត្តដល់អញ នោះអញបានស្តាប់ឯង ហើយក្នុងថ្ងៃសង្គ្រោះ នោះអញបានជួយដល់ឯង" មើល ឥឡូវនេះជាវេលាដែលគាប់ព្រះហឫទ័យទ្រង់ មើលថ្ងៃនេះជាថ្ងៃសង្គ្រោះហើយ " ។

មិនដែលបំភ្លេចថា ព្រះអាទិត្យនឹងលិចជាចុងក្រោយនៅថ្ងៃជាឱកាសរបស់អ្នក ។ "ឥឡូវនេះជាថ្ងៃសង្គ្រោះ " កូរិនថូសទី២ ៦:២ ។

នៅពេលនោះ "ថ្ងៃនេះ នៅពេលអ្នកឮសំលេងរបស់ទ្រង់ " (ហេព្រើ ៣:៧ និងមើល ទំនុកដំកើង ៩៥៣៧) ។

"ចូរស្វែងរកព្រះយេហូវ៉ា ក្នុងកាលដែលអាចនឹងរកទ្រង់ឃើញ ហើយអំពាវនាវដល់ទ្រង់ ក្នុងកាលដែលទ្រង់ គង់នៅជិតចុះ " អេសាយ ៥៥:៦

ឥឡូវពេលវេលាមកដល់ហើយ !